សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ប្រាតិភោគដោយអនុប្បទាន

ស្រាវជ្រាវពីថ្ងៃទី០១ ខែមេសា ឆ្នាំ ២០១៨ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០១៨

តាក់តែងឡើងដោយ

និស្សិតឈ្មោះ **ម៉ុន ស្រីស្រស់**

សាស្ត្រាចារ្យណែនាំ

លោក **ញឹក ឧត្តរ**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី ១៨

ឆ្នាំចូលសិក្សា ២០១៤

ឆ្នាំសរសេរសារណា ២០១៨

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ប៊ុន ស្រីស្រស់** ជានិស្សិតផ្នែកនីតិសាស្រ្តជំនាន់ទី និងជានិស្សិតថ្នាក់នីតិសាស្រ្ត ភាសាខ្មែរ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។

*ខ្ញុំសូមសំដែងសេចក្តីគោរពដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ៖*

១. អ្នកម្តាយ **សុខ គៀន** និងលោកឪពុក **ប៊ុន លី** ដែលបានបង្កើត និងខិតខំចិញ្ចឹមបីបាច់ថែរក្សារូបនាងខ្ញុំ ព្រមទាំងប្រៀនប្រដៅ និងផ្តល់ឪកាសដល់រូបនាងខ្ញុំជាកូនរៀនសូត្រដើម្បីទទួលបាននូវចំណេះដឹង ក្លាយជាកូនល្អ សិស្សល្អ និងពលរដ្ឋល្អ។ មិនតែប៉ុណ្ណោះ អ្នកទាំងពីរក៏តែងតែជួយទំនុកបម្រុង និងផ្តល់នូវកម្លាំងចិត្តក្នុងផ្លូវជីវិតរបស់រូបខ្ញុំ ចាប់តាំងពីតូចមកដល់សព្វថ្ងៃនេះ ពុំនោះទេប្រហែលជាខ្ញុំមិនមានលទ្ធផលល្អដូចពេលបច្ចុប្បន្នឡើយ។

២. លោក **ញឹក ឧុត្ធី** សាស្រ្តាចារ្យនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ព្រមទាំងជាគ្រូដឹកនាំផ្ទាល់ក្នុងការចងក្រងសារណារមួយនេះ។ ក្នុងការស្រាវជ្រាវសរសេរលើប្រធានបទមួយនេះ លោកគ្រូបានផ្តល់នូវដំបូន្មានដ៏ល្អ ហើយជួយដឹកនាំណែនាំ និងចែករំលែកនូវបទពិសោធន៍យ៉ាងច្រើន ជូនដល់រូបនាងខ្ញុំ ដោយមិនគិតពីការខាតបង់ពេលវេលា ភាពនឿយហត់ និងភាពមមាញឹកក្នុងការបង្រៀនរបស់ខ្លួន ហើយបានចំណាយពេលដើម្បីជួយណែនាំ និងកែសម្រួលការចងក្រងសារណារនេះឡើង។

នាងខ្ញុំសូមលើកដៃសំដែងនូវភាពកត្តញ្ញូតាធម៌ និង ការបង្ហាញនូវគុណបំណាច់ដ៏ថ្លៃថ្លាជូនពរដល់ លោកឪពុក អ្នកម្តាយ ថ្នាក់ដឹកនាំ និងលោកសាស្រ្តាចារ្យទាំងអស់អោយជួបប្រទះតែនឹងពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រមរដ្ឋប្បវេណីត្រូវបានប្រកាសឲ្យប្រើនូវឆ្នាំ ២០០៧ ដែលក្នុងនោះមានបញ្ញត្តិថ្មីមួយចំនួនត្រូវបានបង្កើតឡើង ដើម្បីឲ្យស្របទៅនឹងបដិបទនៃសង្គមខ្មែរយើង។ ក្នុងនោះ មានបញ្ញត្តិថ្មីពាក់ព័ន្ធទៅនឹងរឿងរ៉ាវបុគ្គលឯកជន ដូចជា ញាតិ និង ទ្រព្យសម្បត្តិជាដើម ដែលបានបង្កឲ្យការរស់នៅរបស់ប្រជាជនកម្ពុជាកាន់តែងាយស្រួល។ តួយ៉ាង ការបង្កើតបញ្ញត្តិថ្មីៗទាំងអស់នោះនៅតែឃើញថាតម្រូវឲ្យមានការបកស្រាយកាន់តែច្រើន ដើម្បីឲ្យការអនុវត្តប្រព្រឹត្តទៅដោយត្រឹមត្រូវ និងជៀសវាងការភ័ន្តច្រឡំ។

សារណាមួយនេះ ដែលផ្តោតចំបងទៅលើប្រធានបទ ប្រាតិភោគដោយអនុប្បទាន គឺជាអត្ថបទដែលសំខាន់មួយក្នុងសង្គមកម្ពុជាយើង ហើយដែលនាងខ្ញុំបានសម្រេចចិត្តធ្វើការសិក្សាស្រាវជ្រាវចងក្រងនូវខ្លឹមសារទាំងឡាយនេះឡើង ទុកគ្រាន់ជាឯកសារទៅថ្ងៃខាងមុខ។ ដោយហេតុថា ការរស់នៅក្នុងសង្គមយើងមិនជៀសឆ្ងាយបញ្ហាសេដ្ឋកិច្ចនោះទេ ជាពិសេសដូចជាពាណិជ្ជករ វិនិយោគិន ជាដើម។ ដូចនេះហើយ ប្រាតិភោគដោយអនុប្បទាននេះគឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ដែលជាជំនួយដល់ការអនុវត្តរបស់ប្រជាពលរដ្ឋគ្រប់រូប។

គោលបំណងនៃសារណានេះ គឺសង្ឃឹមថារបាយការណ៍បញ្ចប់ការសិក្សាមួយនេះនឹងជាជំនួយអាចជួយដល់ និស្សិត អ្នកសិក្សាស្រាវជ្រាវ និងបុគ្គលទាំងឡាយដែលមានបំណងចង់យល់ដឹងកាន់តែច្បាស់អំពីប្រាតិភោគដោយអនុប្បទាន។

ដោយហេតុថា ការសិក្សាស្រាវជ្រាវចងក្រងសារណានេះ អាចនឹងមាននូវចន្លោះខ្វះខាតមួយចំនួនដែលនឹងត្រូវធ្វើកែរតម្រូវនូវពេលខាងមុខ ដូចនេះនាងខ្ញុំសូមអភ័យទោសជាមុននូវរាល់កំហុសឆ្គងនៅក្នុងសារណានេះ។ ហើយខ្ញុំក៏សង្ឃឹមយ៉ាងមុតមាំថា សារណាមួយនេះ នឹងក្លាយទៅជាចំណេះដឹងថ្មីរបស់អ្នកអានទាំងឡាយ ចំពោះប្រធានបទប្រាតិភោគដោយអនុប្បទាននេះផងដែរ។

# ឯកសារយោង

## ❖ លិខិតបទដ្ឋានគតិយុត្ត

- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០/ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០០៧
- ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ឆ្នាំ ២០០៧
- ប្រកាសស្តីពីអត្រាការប្រាក់ លេខ១២៨កយ.ប្រក/,២១ ខែធ្នូ ឆ្នាំ ២០១១
- ប្រកាសស្តីពីការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន លេខ ០៣០ សហវ.ប្រក

## ❖ ឯកសារផ្សេងៗ

- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៤ ឆ្នាំ ២០១០
- សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ១ ឆ្នាំ២០១៣
- សៀវភៅ នីតិប្រាតិភោគ ឆ្នាំ ២០១០ - ២០១១ ដោយលោកស្រី ចាំង ស៊ីណាត

# មាតិកា

ទំព័រ


**សេចក្ដីផ្ដើម**............................................................................................................១

**ជំពូកទី ១៖ របបគតិយុត្តនៃប្រាតិភោគដោយអនុប្បទាន**

**ផ្នែកទី ១៖ សញ្ញាណទូទៅនៃប្រាតិភោគដោយអនុប្បទាន** ...............................................៤

កថាភាគទី ១៖ ប្រភពនៃប្រាតិភោគដោយអនុប្បទាន...................................................៥

កថាភាគទី ២៖ គោលបំណង និង ផលប្រយោជន៍នៃការបង្កើតប្រាតិភោគដោយអនុប្បទាន ......................................................................................................................៦

**ផ្នែកទី ២៖ លក្ខខណ្ឌសុពលភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន**............................ ៧

កថាភាគទី ១៖ ការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន........................................... ៧

១. លក្ខខណ្ឌគ្រឹះ...........................................................................................៨

២. លក្ខខណ្ឌទម្រង់...................................................................................... ១៤

៣. លក្ខខណ្ឌតតាំង ..................................................................................... ១៥

កថាភាគទី ២៖ ការផ្ទេរការកាន់កាប់....................................................................... ១៦

១. ការប្រគល់ដោយជាក់ស្ដែង ....................................................................... ១៦

២. ការប្ដូរលក្ខណៈនៃការកាន់កាប់ ................................................................ ១៦

៣. ការប្រគល់ដោយសង្ខេប ......................................................................... ១៧

៤. ការផ្ទេរការកាន់កាប់ដោយបញ្ញា ............................................................... ១៧

**ជំពូកទី ២៖ អានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន**

**ផ្នែកទី១៖ អានុភាពចំបង**.......................................................................................... ១៩

កថាភាគទី ១៖ អានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទានចំពោះវត្ថុ ........................ ១៩

១. ទំហំនៃសិទ្ធិដែលមានអានុភាព................................................................២០

២. លក្ខណៈនៃវត្ថុដែលជាកម្មវត្ថុ ...................................................................២០

២.១. សមាសភាគនៃវត្ថុ......................................................................................២០
២.២. វត្ថុដែលភ្ជាប់នឹងកម្មវត្ថុនៃប្រាតិភោគ.....................................................២១
២.៣. វត្ថុដែលជាផ្នែកនៃវត្ថុដែលជាកម្មវត្ថុ.......................................................២២
កថាភាគទី ២៖ អានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទានចំពោះផល .....................២២
១. ករណីអនុប្បទាយីកាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ.........................២៣
២. ករណីអនុប្បទានិកកាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ ........................២៣
កថាភាគទី ៣៖ អានុភាពនៃសិទ្ធិលើបំណុលដែលជាកាតព្វកិច្ច.................................២៤
១. ប្រាក់ដើម និង តម្លៃការប្រាក់ ................................................................២៥
២. សំណងប្រាក់នៃទំហំកាតព្វកិច្ច..................................................................២៦
៣. វិការៈ និងការមិនអនុវត្តកាតព្វកិច្ច ............................................................២៦
**ផ្នែកទី២៖ អានុភាពដោយខ្សែក** ...............................................................................២៦
កថាភាគទី ១៖ ឧបាទេសកម្មលើវត្ថុ.............................................................................២៦
១. ចលនវត្ថុធម្មតា ..........................................................................................២៧
២. ចលនវត្ថុផ្គុំគ្នា.............................................................................................២៨
កថាភាគទី ២៖ បញ្ញត្តិពិសេស.......................................................................................២៨
១. អានុភាពឃាត់ទុក និង ទទួលបានសោហ៊ុយ ...............................................២៩
២. ការទទួលបាននូវលទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ.................. ៣០

**ជំពូកទី ៣៖ ដំណើរប្រព្រឹត្តទៅនៃប្រាតិភោគដោយអនុប្បទាន**

**ផ្នែកទី១៖ ការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាននៅក្នុងព្រះរាជាណាចក្រកម្ពុជា** .
............................................................................................................................ ៣២
កថាភាគទី ១៖ កិច្ចដំណើរការនៃការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន .............៣៣
កថាភាគទី ២៖ ការចាត់ចែងវត្ថុ.....................................................................................៣៣
១. ការប្តូរវត្ថុដែលជាកម្មវត្ថុជាប្រាក់ ............................................................... ៣៤
២. អនុប្បទានជាស្ថាពរ.................................................................................... ៣៤

កថាភាគទី ៣៖ ការប្រគល់វត្ថុដែលជាកម្មវត្ថុឲ្យអ្នកបង្កើត........................................ ៣៥
**ផ្នែកទី២៖ ហានិភ័យ និង អាជ្ញាយុកាល** .......................................................................... ៣៦
កថាភាគទី ១៖ ហានិភ័យដែលអាចកើតមានឡើង.................................................... ៣៦
១. ករណីពាក់ព័ន្ធនឹងម្ចាស់បំណុល ................................................................ ៣៧
២. ករណីពាក់ព័ន្ធនឹងកូនបំណុល.................................................................... ៣៨
កថាភាគទី ២៖ អាជ្ញាយុកាលនៃកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន ....................... ៤០
**សេចក្តីសន្និដ្ឋាន**............................................................................................................... ៤១
**អនុសាសន៍**......................................................................................................................... ៤៣
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ក្នុងការរស់នៅក្នុងសង្គមមួយសព្វថ្ងៃ បញ្ហាសេដ្ឋកិច្ចជាបញ្ហាមួយដែលមនុស្សស្ទើរតែគ្រប់រូបជួបប្រទះ ចំណែកឯក្នុងការរស់នៅវិញ តម្រូវការផ្នែកសេដ្ឋកិច្ចក៏មានភាពកើនឡើងឥតឈប់ឈរ ដែលមនុស្សគ្រប់ស្រទាប់វណ្ណៈតែងរិះរកនូវគ្រប់មធ្យោបាយក្នុងការសម្រួលនូវកត្តាលំបាកមួយនេះ។ អាស្រ័យបញ្ហាហិរញ្ញវត្ថុទាំងនេះហើយ បានធ្វើឲ្យមនុស្សមួយចំនួនធំធ្វើកិច្ចប្រតិបត្តិការខ្ចីប្រាក់ ដែលជាមធ្យោបាយមួយអាចជួយសម្រួលដល់បញ្ហាសេដ្ឋកិច្ចរបស់ពួកគេក្នុងពេលអាសន្ន។ ជាក់ស្តែង ក្នុងការអនុវត្តកន្លងមកនេះ ការខ្ចីប្រាក់អាចប្រព្រឹត្តទៅបានតាមវិធីជាច្រើន ដែលវិធីខ្លះមានលក្ខណៈងាយស្រួល និងខ្លះមានភាពស្មុគស្មាញ។ តាមផ្លូវច្បាប់ យើងឃើញមានប្រតិបត្តិការដូចជាការធ្វើកិច្ចសន្យាខ្ចីបរិភោគ ដែលជាកិច្ចសន្យាខ្ចីប្រាក់ មានភាពនិយមបំផុតនៅក្នុងសង្គម។

ទោះបីជាយ៉ាងណាក៏ដោយ ការខ្ចីប្រាក់តាមវិធីនេះរមែងតែងកើតមានឡើងនូវវិបត្តជាច្រើន ដែលបណ្តាលឲ្យប្រតិបត្តិការនេះដំណើរការទៅមានឧបស័គ្គមួយចំនួន ដូចជា កូនបំណុលមិនធ្វើការសងប្រាក់មកកាន់ម្ចាស់បំណុលវិញ ឬការសងនោះមានភាពយឺតយ៉ាវ ហើយម្ចាស់បំណុលមិនមានមធ្យោបាយអ្វីដើម្បីធានាថាខ្លួននឹងទទួលបានប្រាក់នោះពិតប្រាកដវិញឡើយ។ ទន្ទឹមនឹងនេះដែរ ជំនឿទុកចិត្តរបស់ម្ចាស់បំណុលក៏នៅមានកម្រិតផងដែរ ក្នុងការផ្តល់ប្រាក់កម្ចីនេះ ដោយហេតុថាកន្លងមកតែងកើតមានឡើងនូវបញ្ហាជាញឹកញាប់ ដែលភាគច្រើនគឺអ្នកខាតបង់ច្រើនតែជាម្ចាស់បំណុល។

ដោយឡែក ក្រមរដ្ឋប្បវេណីក៏មានចែងនូវការខ្ចីប្រាក់ប្រភេទផ្សេងទៀត ដែលគេហៅថាប្រាតិភោគប្រត្រក្យ។ ប្រាតិភោគប្រត្យក្ស គឺជាសិទ្ធិប្រត្យក្សមួយប្រភេទ ដែលប្រគល់ឲ្យម្ចាស់បំណុលនូវសិទ្ធិពិសេស ជាអាទិ៍ ការឃាត់ទុក ឯកសិទ្ធិលើកូនបំណុល ដែលទាំងនេះគឺជាប្រាតិភោគដែលបង្កើតឡើងដោយច្បាប់។ ចំណែកឯ ប្រាតិភោគដែលបង្កើតដោយកិច្ចសន្យាវិញ រួមមាន ហ៊ីប៉ូតែក ការបញ្ចាំ និង ប្រាតិភោគដោយអនុប្បទាន។ ដោយសារតែសង្គមយើងមានការវិវឌ្ឍន៍ក្នុងរបបសេដ្ឋកិច្ចទីផ្សារសេរី ការខ្ចីប្រាក់ក៏កាន់តែមានការកើនឡើងខ្ពស់ ព្រោះមនុស្សជាច្រើនបានកើតមាននូវគំនិតរកចំណូល ដោយរកស៊ីប្រកបមុខរបរ។ សិទ្ធិប្រាតិភោគប្រត្យក្ស ត្រូវបានបង្កើតឡើងតាមបញ្ញត្តិច្បាប់ ឬ តាមការព្រមព្រៀង ដែលត្រូវបានបញ្ញត្តិក្នុងច្បាប់នៅក្នុងគន្ថីទី ៦ ស្តីពីការធានាកាតព្វកិច្ច។ ក្នុងនោះ ប្រធានបទនៃសារណានេះនឹងផ្តោតសំខាន់តែលើប្រាតិភោគដោយអនុប្បទាន ដែលនេះជាសិទ្ធិប្រាតិភោគប្រត្យក្សថ្មីមួយ មានប្រភពចេញពីប្រទេសជប៉ុន។ ប្រាតិភោគដោយអនុប្បទានពុំទាន់សូវមានភាពពេញនិយមនៅក្នុងបដិបទនៃសង្គមកម្ពុជាយើងឡើយ មូលហេតុដោយសារថាបុគ្គលក្នុងសង្គមភាគច្រើនមិនសូវបានជ្រាបជាពត៌មាន ឬ យល់ដឹងអំពីថា

តើអ្វីទៅជាប្រាតិភោគដោយអនុប្បទាន ឬ ថាតើប្រាតិភោគដោយអនុប្បទាននេះត្រូវបានបង្កើតឡើងយ៉ាងដូចម្តេច ឬ ការអនុវត្តគឺប្រព្រឹត្តទៅយ៉ាងណា។ លើសពីនេះទៅទៀត មនុស្សក្នុងសង្គមខ្លះមិនត្រឹមតែមិនបានយល់ដឹងអំពីប្រាតិភោគដោយអនុប្បទាននោះទេ បុគ្គលមួយចំនួនដែលបានយល់ដឹងខ្លះហើយក៏ហាក់បីដូចជាមានការយល់ច្រឡំរវាងប្រាតិភោគដោយអនុប្បទាន និង ការបញ្ចាំ ហេតុដូចនេះហើយបានធ្វើឲ្យមានការភ័ន្តច្រឡំតៗគ្នាក្នុងការអនុវត្តកន្លងមកនេះ។

ចម្ងល់ដែលចោទឡើងខាងលើ អាចក្លាយជាបញ្ហាចោទដ៏សំខាន់មួយនៅក្នុងបដិបទនៃសង្គមកម្ពុជាយើង ដែលជាមូលហេតុតម្រូវឲ្យមានការបកស្រាយ និង ស្រាវជ្រាវបន្ថែមដើម្បីកាត់បន្ថយនូវការភ័ន្តច្រឡំ និង ដើម្បីជាជំនួយស្មារតីផងដែរទៅដល់បុគ្គលទាំងឡាយណាត្រូវការពត៌មានបន្ថែមអំពីប្រាតិភោគដោយអនុប្បទាន។ មូលហេតុដូចបានលើកឡើងខាងលើនេះ បានកើតជាគោលគំនិតមួយដែលញ៉ាំងឲ្យនាងខ្ញុំមានបំណងចង់ធ្វើការចងក្រង នូវសារណានេះឡើងដោយរំពឹងទុកថានឹងអាចជួយដោះស្រាយនូវបញ្ហានៅក្នុងសង្គម ក៏ដូចជាកាត់បន្ថយនូវវិវាទដែលអាចនឹងកើតមានឡើងក្នុងប្រតិបត្តិការនៃការខ្ចីប្រាក់។ គួរបញ្ជាក់ផងដែរថា វិសាលភាពនៃខ្លឹមសារនៅក្នុងសារណានេះនឹងផ្តោតសំខាន់ទៅលើប្រាតិភោគដោយអនុប្បទានតែប៉ុណ្ណោះ ដោយហេតុតែឃើញថាប្រាតិភោគប្រត្យក្សប្រភេទនេះ មានលក្ខណៈថ្មីស្រឡាង កង្វះខាតនូវឯកសារ ចំណែកឯការអនុវត្តវិញក៏មិនសូវប្រទះជួបផងដែរ ដែលនេះហើយជាហេតុតម្រូវឲ្យមានការសិក្សាឲ្យបានកាន់តែស៊ីជម្រៅជាងនេះ។

ដូចនេះ ដើម្បីឲ្យមានភាពងាយស្រួលក្នុងការបកស្រាយនូវប្រធានបទសារណានេះ ជាបន្តទៅទៀតខ្ញុំនឹងធ្វើការបែកចែកជាបីជំពូក ពោលគឺៈ

- ជំពូកទី១ ស្តីអំពី របបគតិយុត្តនៃប្រាតិភោគដោយអនុប្បទាន ។
- ជំពូកទី២ ស្តីអំពី អានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ។
- ជំពូកទី៣ ស្តីអំពី ដំណើរប្រព្រឹត្តទៅនៃប្រាតិភោគដោយអនុប្បទាន ។

# ជំពូកទី ១
# របបគតិយុត្តនៃប្រាតិភោគដោយអនុប្បទាន

តាមការអនុវត្តច្បាប់នៅក្នុងបដិបទនៃព្រះរាជាណាចក្រកម្ពុជាកន្លងមក គេពុំដែលបានជួបប្រទះនូវបញ្ហាដែលទាក់ទិនទៅនឹងរឿងប្រាតិភោគដោយអនុប្បទាននោះទេ។ តួយ៉ាងនៅក្នុងក្រមរដ្ឋប្បវេណីចាស់ ដោយត្រូវបានប្រកាសឲ្យប្រើដោយព្រះមហាក្សត្រ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩២០ ដែលជាក្រមរដ្ឋប្បវេណីដំបូងបំផុតនៅក្នុងមតិកគតិយុត្តរបស់កម្ពុជា ក៏យើងពុំឃើញមានបញ្ញត្តិណាមួយស្តីអំពីប្រាតិភោគដោយអនុប្បទាននេះដែរ។ ក្នុងច្បាប់ចាស់ដែលត្រូវបានចងក្រងឡើងដោយលោក អេង សុត នេះ ឃើញមានចែងតែអំពី ការបញ្ចាំអចលនវត្ថុ និង ហ៊ីប៉ូតែក តែប៉ុណ្ណោះ ហើយនេះបានស្តែងឲ្យឃើញពីភាពអវត្តមាននៃករណីធានាកាតព្វកិច្ចតាមប្រភេទប្រាតិភោគដោយអនុប្បទាន។ លុះមកដល់ពេលបច្ចុប្បន្ននេះ ដោយតម្រូវការនៅក្នុងសង្គមមានការផ្លាស់ប្តូរ ទើបយើងឃើញមានប្រភេទប្រាតិភោគថ្មីមួយបន្ថែមទៀត នៅក្នុងប្រភេទនៃប្រាតិភោគប្រត្យក្ស ដែលនោះគឺប្រាតិភោគដោយអនុប្បទាន។ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានរដ្ឋសភាអនុម័ត នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំលើកទី៧ នីតិកាលទី៣ និងត្រូវបានព្រឹទ្ធសភាយល់ស្រប នៅថៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៤ នីតិកាលទី២ ដោយប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ និងចូលជាធរមានទៅតាមការកំណត់របស់ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ហើយប្រកាសអោយប្រើនៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ មានបញ្ញត្តិអំពី ប្រាតិភោគដោយអនុប្បទាន។ ក្នុងក្រមរដ្ឋប្បវេណីបានកំណត់ប្រាតិភោគដោយអនុប្បទាន ជាប្រភេទមួយនៃប្រាតិភោគប្រត្យក្ស ដែលត្រូវបានចង្អុលបង្ហាញនៅក្នុងជំពូកទី៦ នៃគន្ថីទី៦ ស្តីពីការធានាកាតព្វកិច្ច។ ដោយហេតុថាប្រធានបទសារណារនេះផ្តោតសំខាន់តែលើប្រភេទមួយនៃសិទ្ធិប្រត្យក្សដូច្នេះហើយ សារណារនេះនឹងមិនធ្វើការបកស្រាយទៅលើសិទ្ធិប្រត្យក្សផ្សេងក្រៅពីប្រាតិភោគដោយអនុប្បទាននេះឡើយ។ ក្នុងការបង្ហាញអំពីរបបគតិយុត្តនៃប្រាតិភោគដោយអនុប្បទានឲ្យកាន់តែងាយស្រួលយល់ និង ច្បាស់លាស់ក្នុងការបកស្រាយបន្តទៅនេះ ការអត្ថាធិប្បាយនឹងធ្វើការចង្អុលបង្ហាញនូវសញ្ញាណទូទៅនៃប្រាតិភោគដោយអនុប្បទាន (ផ្នែកទី ១) និង ល័ក្ខខ័ណ្ឌសុពលភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន (ផ្នែកទី ២)។

## ផ្នែកទី ១៖ សញ្ញាណទូទៅនៃប្រាតិភោគដោយអនុប្បទាន

ដើម្បីធ្វើឲ្យការបកស្រាយកាន់តែងាយយល់ និង មុននឹងឆ្វេងយល់អំពី ប្រាតិភោគដោយអនុប្បទាន ជាបឋម យើងត្រូវយល់នូវពាក្យ "ប្រាតិភោគ" និង ពាក្យ "អនុប្បទាន" ជាមុនសិន។ បើយោងទៅតាមសទ្ទានុក្រមផ្នែករដ្ឋប្បវេណី ដែលដកស្រង់ពី "សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ~អង់គ្លេស~បារាំង ផ្នែករដ្ឋប្បវេណី និង នីតិវិធីរដ្ឋប្បវេណី" ពាក្យថា "**ប្រាតិភោគ**" គឺជាការធានា ដល់ម្ចាស់បំណុលក្នុងការប្រមូលឥណទេយ្យរបស់ខ្លួនមកវិញ ឬ ជាមធ្យោបាយមួយដើម្បីធានាការសងកាតព្វកិច្ច។[1] ចំណែកឯពាក្យ "អនុប្បទាន" វិញមានអត្ថន័យថាជា ការផ្ទេរសិទ្ធិ ឬ ទ្រព្យសម្បត្តិរបស់បុគ្គលណាម្នាក់ដែលជាអនុប្បទាយី ទៅឲ្យបុគ្គលម្នាក់ទៀតដែលជាអនុប្បទានិក។[2] ដូចនេះ ពាក្យថា "ប្រាតិភោគដោយអនុប្បទាន" បានសេចក្តីថាជាកិច្ចធានាមួយដល់ម្ចាស់បំណុល តាមរយៈការផ្ទេរសិទ្ធិ ឬ ទ្រព្យសម្បត្តិរបស់អនុប្បទាយី ដើម្បីធានាដល់អនុប្បទានិកក្នុងការប្រមូលឥណទេយ្យរបស់ខ្លួនមកវិញ។ ដោយឡែក នៅក្នុងក្រមរដ្ឋប្បវេណីយើង មាត្រា ៨៨៨ ក៏បានផ្តល់នូវនិយមន័យនៃប្រាតិភោគដោយអនុប្បទានផងដែរ ដែលក្នុងនោះបានចែងថា *"ប្រាតិភោគដោយអនុប្បទានសំដៅទៅលើការណ៍ដែលកូនបំណុល ឬ តតិយជនធ្វើអនុប្បទាននូវចលនវត្ថុរបស់ខ្លួនជាកំណាត់ទៅឱ្យម្ចាស់បំណុល ដើម្បីធានាកាតព្វកិច្ច។*[3]" អត្ថន័យដែលបានចែងនៅក្នុងកថាខណ្ឌទី ១ នេះ ចង់ផ្តោតសំខាន់ថា កម្មសិទ្ធិត្រូវបានផ្ទេរដើម្បីបង្កើតសិទ្ធិប្រត្យក្ស ហើយចែងផងដែរថា កម្មសិទ្ធិត្រូវផ្ទេរទៅកូនបំណុល ដោយការសងកាតព្វកិច្ច។[4]

ពិសេសជាងនេះទៅទៀត យើងគួរកត់សម្គាល់នូវពាក្យថា **ចលនវត្ថុ** នៅក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ដោយបានសេចក្តីថា ប្រាតិភោគដោយអនុប្បទាន គឺអាចបង្កើតឡើងចំពោះតែចលនវត្ថុតែប៉ុណ្ណោះ ពោលគឺបើអនុវត្តចំពោះអចលនវត្ថុវិញ ដូចជា ដីធ្លី ឬ ផ្ទះ គេអាចអនុវត្តនូវបទប្បញ្ញត្តិប្រភេទផ្សេងនៃសិទ្ធិប្រាតិភោគប្រត្យក្ស ដូចជា ការបញ្ចាំ ឬ ហ៊ីប៉ូតែក ជាដើម។ ក្រមរដ្ឋប្បវេណីថ្មីបានបញ្ញត្តិអំពីការបញ្ចាំអចលនវត្ថុ ក្នុងគន្ថីទី ៦ ចាប់ពីមាត្រា ៨៣៤ ដល់មាត្រា ៨៣៩[5] និង បានបញ្ញត្តិអំពីហ៊ីប៉ូតែក ក្នុងមាត្រា ៨៤៤ យ៉ាងច្បាស់ថា ហ៊ីប៉ូតែកនឹងត្រូវបានបង្កើតឡើង

---

1 គណកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, សទ្ទានុក្រមផ្នែករដ្ឋប្បវេណី, បោះពុម្ពដោយទីស្តីការគណៈរដ្ឋមន្ត្រី, ឆ្នាំ ២០០៧ (ហៅថា សទ្ទានុក្រមផ្នែករដ្ឋប្បវេណី), ទំព័រ ១៩។

2 គណកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, សទ្ទានុក្រមផ្នែករដ្ឋប្បវេណី, បោះពុម្ពដោយទីស្តីការគណៈរដ្ឋមន្ត្រី, ឆ្នាំ ២០០៧ (ហៅថា សទ្ទានុក្រមផ្នែករដ្ឋប្បវេណី), ទំព័រ ២៧។

3 ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, មាត្រា ៨៨៨.១។

4 ក្រសួងយុត្តិធម៌, សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០១០, ភាគ៤ គន្ថីទី៦, ទំព័រ ១០២។

5 ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, គន្ថីទី ៦។

ដោយការព្រមព្រៀងគ្នារវាងម្ចាស់បំណុល និង កូនបំណុល ឬ តតិយជនដែលយកអចលនវត្ថុរបស់ខ្លួនមកដាក់ជាប្រាតិភោគ។[6] នៅក្នុងមាត្រា ៨៨៨ ដដែល កថាខណ្ឌទី ២ បានចែងទៀតថា *ចលនវត្ថុច្រើន ដែលត្រូវបានកំណត់ទំហំតាមមាត្រដ្ឋាន ដូចជាប្រភេទ ឬ កន្លែងស្ថិតនៅនៃចលនវត្ថុ អាចយកមកធ្វើជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ដោយចាត់ទុកជាចលនវត្ថុផ្ដុំគ្នាតែមួយបាន ទោះបីជាចលនវត្ថុនីមួយៗដែលផ្ដុំគ្នានោះ មានការប្រែប្រួលក៏ដោយ។*[7] ក្នុងអត្ថន័យនេះ គេចង់សំដៅថា ប្រាតិភោគដោយអនុប្បទានអាចបង្កើតលើចលនវត្ថុផ្ដុំគ្នាបាន។[8] ជាឧទាហរណ៍ចំពោះករណីចលនវត្ថុផ្ដុំគ្នានេះ ខ្ញុំសូមលើកយកករណីសិក្សាមួយមកបង្ហាញមិត្តអ្នកអានទាំងឡាយ។ ស្រមៃថា លោក ក ចង់ធ្វើការពង្រីកបឹងចញ្ចឹមត្រីរបស់ខ្លួន ដើម្បីស្វែងរកប្រាក់ចំណូលបន្ថែម ដូចនេះ លោក ក ក៏បានសម្រេចចិត្តខ្ចីប្រាក់ពី លោក ខ ដោយបង្កើតប្រាតិភោគដោយអនុប្បទានលើ បឹងចញ្ចឹមត្រីរបស់ខ្លួន ដែលសរុបមានសត្វត្រីចំនួន ១០០០០ ក្បាលរស់នៅក្នុងបឹងនោះ។ ដូចក្នុងករណីដែលបានលើកឡើងនេះ សត្វត្រីទាំងឡាយដែលមាននៅក្នុងបឹងនឹងក្លាយទៅជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន បើទោះបីជាលោក ក បានលក់សត្វត្រីខ្លះចេញ និង ទិញសត្វត្រីខ្លះចូលវិញក៏ដោយ។

ដូចបានបកស្រាយខាងលើនេះ ប្រាតិភោគអនុប្បទាន ជាប្រតិបត្តិការខ្ចីប្រាក់មួយដែលការធ្វើអនុប្បទាននៅក្នុងករណីនេះ សំដៅលើការផ្ទេរកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុទៅឲ្យម្ចាស់បំណុលជាបណ្ដោះអាសន្នរហូតដល់ពេលកាតព្វកិច្ចត្រូវបានអនុវត្តរួចរាល់។ ការធ្វើប្រាតិភោគប្រភេទនេះពុំចាំបាច់ទាល់តែកូនបំណុលធ្វើការផ្ទេរការកាន់កាប់លើវត្ថុដែលជាកម្មវត្ថុដោយផ្ទាល់ឡើយ ពោលគឺ កូនបំណុលនៅតែអាចបន្តកាន់កាប់ និង អាស្រ័យផលទៅលើវត្ថុនោះដដែល ដែលនេះហើយញ៉ាំងឲ្យប្រាតិភោគដោយអនុប្បទានមានលក្ខណៈខុសប្លែកពីប្រាតិភោគដទៃទៀត។

### កថាភាគទី ១៖ ប្រភពនៃប្រាតិភោគដោយអនុប្បទាន

យើងដឹងហើយថា ក្រមរដ្ឋប្បវេណីកម្ពុជាមានភាពសាយភាយឥទ្ធិពលមិនត្រឹមតែពីក្រមរដ្ឋប្បវេណីជប៉ុននោះទេ តែទទួលឥទ្ធិពលពីច្បាប់ផ្សេងៗទៀតរបស់ប្រទេសជប៉ុនក្នុងវិស័យឯកជន។ និយាយបែបនេះ ពុំបានសេចក្ដីថា ក្រមរដ្ឋប្បវេណីកម្ពុជាមានអត្ថន័យ និង ខ្លឹមសារដូចទៅនឹងរាល់

[6] ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, មាត្រា ៨៥៤។

[7] ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, មាត្រា ៨៨៨។

[8] ក្រសួងយុត្តិធម៌, សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០១០, ភាគ៤ គន្ថីទី៦, ទំព័រ ១០២។

វិធានគតិយុត្តនៅប្រទេសជប៉ុននោះទេ តែរាល់ការចងក្រងវិធានច្បាប់របស់ប្រទេសកម្ពុជាសុទ្ធសឹងតែឈរលើមូលដ្ឋានគ្រឹះនៃស្ថានភាពជាក់ស្តែង ឬ បដិបទនៅក្នុងសង្គមកម្ពុជាផ្ទាល់តែម្តង។ តួយ៉ាងយើងសង្កេតឃើញថា ប្រាតិភោគដោយអនុប្បទានទើបកើតមានឡើងនៅក្នុងឆ្នាំ ២០០៧ តែប៉ុណ្ណោះ ដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧។ ដោយហេតុមានការសហការជាមួយនឹងភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ដែលនាំឲ្យច្បាប់នៃប្រទេសជប៉ុនជះឥទ្ធិពលមកលើក្រមរដ្ឋប្បវេណីរបស់កម្ពុជា ទើបយើងឃើញមានលេចឡើងនូវសិទ្ធិប្រាតិភោគប្រត្យក្សប្រភេទថ្មីនេះឡើង នោះគឺប្រាតិភោគដោយអនុប្បទាន។ បើយើងពិនិត្យទៅមើលលើក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុន ដែលជាប្រភពនៃក្រមរដ្ឋប្បវេណីនៃប្រទេសកម្ពុជាឆ្នាំ ២០០៧ គឺមិនមានឃើញចែងឡើយអំពីបញ្ញត្តិស្តីពីប្រាតិភោគដោយអនុប្បទាន ពោលគឺការដោះស្រាយរាល់វិវាទលើបញ្ហាទាំងនេះគឺធ្វើឡើងទៅតាមយុត្តិសាស្ត្ររបស់តុលាការនៃប្រទេសជប៉ុន។ អាស្រ័យដូចបានលើកឡើងនេះ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាដែលបានប្រកាសនៅថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០០៧ គឺមិនមែនបានមកពីក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុននោះទេ ពោលគឺបានទទួលយកនូវគោលគំនិតនៃបទប្បញ្ញត្តិ ស្តីពីប្រាតិភោគដោយអនុប្បទាន ដែលចេញពីការអនុវត្តកន្លងមករបស់ប្រទេសជប៉ុនតែប៉ុណ្ណោះ។

### កថាភាគទី ២៖ គោលបំណង និងផលប្រយោជន៍នៃការបង្កើតប្រាតិភោគដោយអនុប្បទាន

ប្រាតិភោគដោយអនុប្បទាន គឺជាការធានាសិទ្ធិលើបំណុលដោយអនុញ្ញាតិឲ្យអ្នកបង្កើតសិទ្ធិប្រាតិភោគអាចប្រើប្រាស់ និង បន្តការកាន់កាប់វត្ថុ ដែលជាកម្មវត្ថុនៃប្រាតិភោគក្នុងកំឡុងពេលនៃការធ្វើប្រាតិភោគដោយអនុប្បទាន។ ជាគោលការណ៍ ប្រាតិភោគដោយអនុប្បទានកម្ពុជាមានលក្ខណៈដូចគ្នាច្រើនទៅនឹងបញ្ញត្តិប្រាតិភោគអនុប្បទាននៅប្រទេសជប៉ុន ហើយទន្ទឹមនឹងការលេចឡើងនៃបញ្ញត្តិនេះ យើងឃើញមានសំណួរចោទសួរជាច្រើនថា តើគេបង្កើតប្រាតិភោគប្រភេទថ្មីនេះឡើងក្នុងគោលបំណងអ្វី ហើយតើវាបានផ្តល់នូវផលប្រយោជន៍អ្វីខ្លះក្នុងសង្គមជាតិយើង?

យើងអាចនឹងឆ្លល់ថា បើច្បាប់បង្កើតឲ្យមាននូវការបញ្ចាំរួចមកហើយ តើចាំបាច់អីដែលត្រូវបង្កើតនូវបទប្បញ្ញត្តិថ្មីមួយទៀត ដែលជាប្រាតិភោគដោយអនុប្បទាននេះឡើង? ប៉ុន្តែ បើមើលទៅលើជ្រុងមួយផ្សេងទៀត ការបង្កើតប្រាតិភោកដោយអនុប្បទាននេះ មានគោលបំណងដោះស្រាយនូវផលវិបាកដែលកើតមានកន្លងមកនៅក្នុងរូបភាពនៃសិទ្ធិលើការបញ្ចាំ។ ហើយលើសពីនេះទៅទៀត វាបានផ្តល់នូវភាពងាយស្រួលទាំងកូនបំណុល និងម្ចាស់បំណុលផងដែរ។ ចំពោះកូនបំណុលក្នុងការខ្ចីប្រាក់បុគ្គលណាម្នាក់ ខ្លួនអាចពុំចាំបាច់ធ្វើការផ្ទេរនូវចលនវត្ថុដោយផ្ទាល់ទៅម្ចាស់បំណុល

នោះឡើយ។ នេះគឺជាគោលបំណងសំខាន់មួយ ហើយក៏ជាគុណប្រយោជន៍មួយ ដែលជាគោលគំនិតបង្កើតឲ្យមានប្រាតិភោគដោយអនុប្បទាននេះឡើង។ លើសពីនេះទៅទៀត សកម្មភាពនៃការខ្ចីប្រាក់ក្នុងរូបភាពជាប្រាតិភោគដោយអនុប្បទាន ពោលគឺការធ្វើអនុប្បទាននូវចលនវត្ថុរបស់ខ្លួនជាកំណាត់ ទៅឲ្យម្ចាស់បំណុល ដើម្បីធានាកាតព្វកិច្ចក្នុងការសងបំណុលរបស់ខ្លួន គឺជាសកម្មភាពមួយដែលកូនបំណុលអាចទទួលបានផលប្រយោជន៍ជាច្រើន ដូចជាអាចគ្រាន់តែធ្វើការផ្ទេរការកាន់កាប់ដោយប្រយោល ហើយខ្លួនអាចនៅតែកាន់កាប់លើចលនវត្ថុដែលបានធ្វើប្រាតិភោគនោះ និងស្វែងរកប្រាក់ចំណូលពីវា។ ដោយឡែក ប្រាតិភោគដោយអនុប្បទានក៏បានផ្តល់ផលប្រយោជន៍ដល់ម្ចាស់បំណុលផងដែរ។ យើងឃើញថា ម្ចាស់បំណុលពុំចាំបាច់រងនូវហានិភ័យ ឬ ទទួលខុសត្រូវលើព្យសនកម្មដែលអាចនឹងកើតមានឡើងទៅលើចលនវត្ថុដែលជាកម្មវត្ថុឡើយ ក្នុងករណីដែលម្ចាស់បំណុលមិនធ្វើការកាន់កាប់លើវត្ថុនោះ។ ក្រៅពីគុណប្រយោជន៍លើកឡើងខាងលើនេះ នីតិវិធីនៃការធ្វើកម្ចីតាមប្រាតិភោគដោយអនុប្បទានក៏មិនមានភាពស្មុគស្មាញផងដែរ ពោលគឺដំណើរការទាំងអស់អនុវត្តតាមក្រៅផ្លូវតុលាការ លើកលែងករណីដែលមានវិវាទកើតមានឡើង។ ប៉ុន្តែ ទោះបីជាការបង្កើតប្រាតិភោគដោយអនុប្បទាននេះមានគុណសម្បត្តិជាច្រើនក្តី ទន្ទឹមនឹងនោះ ក៏វាកើតមានផងដែរនូវគុណវិបត្តដែលគួរឲ្យកត់សម្គាល់ ពោលគឺត្រង់ចំណុចដែលថា ម្ចាស់បំណុលមិនបានកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទានដោយផ្ទាល់ ដែលក្នុងចំណុចនេះអាចបណ្តាលឲ្យមានវិវាទកើតឡើង។ វិវាទរួមមានដូចជា អ្នកបង្កើតប្រាតិភោគនោះធ្វើការលក់ដូរ ឬ ចាត់ចែងលើវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគ ឬ អ្នកបង្កើតយកវត្ថុដែលជាកម្មវត្ថុនោះរត់ចោលស្រុកជាដើម។ បញ្ហាទាំងអស់នេះសុទ្ធសឹងតែអាចនឹងកើតមានឡើងដែលយើងគួរធ្វើការពិចារណាផងដែរ។

## ផ្នែកទី ២៖ លក្ខខណ្ឌសុពលភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

### កថាភាគទី ១៖ ការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបានធ្វើការបញ្ជាក់យ៉ាងច្បាស់ នៅក្នុងជំពូកទោលនៃគន្ថីទី ១ ស្តីពី បទប្បញ្ញត្តិទូទៅ ដែលបានបង្ហាញពីគោលការណ៍សំខាន់ៗដែលបុគ្គលនីមួយៗតម្រូវត្រូវគោរព និង ប្រតិបត្តិតាម។ ជាក់ស្តែង យើងឃើញថា ក្រមរដ្ឋប្បវេណី កំណត់អំពីគោលការណ៍នៃការធានាសេចក្តីថ្លៃថ្នូររបស់បុគ្គល ភាពស្មើគ្នា របស់បុរស នារី និង សិទ្ធិលើទ្រព្យសម្បត្តិ ដែលត្រូវបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ។[១] លើសពីនេះទៅទៀត មាត្រា ៣ មាត្រា ៤ និង មាត្រា ៥ នៃក្រមរដ្ឋប្បវេណីក៏បានលើកពីគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន ពោលគឺត្រូវ

[១] ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ២។

គោរពនូវសេរីភាពនៃឆន្ទៈរបស់បុគ្គលឯកជន និង មិនត្រូវប្រើប្រាស់សិទ្ធិរបស់ខ្លួន ដោយបំពានហួសពីទំហំនៃការការពារ ក៏ដូចជាគោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់នោះទេ។

សិទ្ធិប្រាតិភោគប្រត្យក្សត្រូវបានបង្កើតឡើងដើម្បីធានាកាតព្វកិច្ច ហើយដែលសិទ្ធិនេះមិនអាចត្រូវបានបង្កើតឡើងដោយឯកឯង និងឯករាជ្យបាននោះទេ គឺត្រូវបង្កើតឡើងដោយមានការព្រមព្រៀងគ្នាជាមួយនឹងគូរភាគីនៃកិច្ចសន្យា ព្រមទាំងត្រូវគោរពនូវគោលការណ៍មូលដ្ឋាននៃក្រមរដ្ឋប្បវេណីកម្ពុជាយើងផងដែរ។ ម្យ៉ាងវិញទៀត ប្រាតិភោគដោយអនុប្បទាន គឺជាប្រភេទមួយក្នុងចំណោមសិទ្ធិប្រាតិភោគប្រត្យក្ស ដែលនិយាយលម្អិតជាងនេះ គឺជាប្រភេទនៃសិទ្ធិប្រាតិភោគប្រត្យក្សកំណត់ដោយកិច្ចសន្យា។ ហេតុនេះហើយ ក្នុងការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាននេះរមែងត្រូវគោរពយ៉ាងខ្ជាប់ខ្ជួននូវល័ក្ខខ័ណ្ឌសំខាន់ៗ ដែលអាចឈានទៅដល់សុពលភាពនៃកិច្ចសន្យា។ បញ្ញត្តិដែលបង្កើតឡើងទាក់ទិននឹងប្រាតិភោគដោយអនុប្បទានគឺដើម្បីដោះស្រាយនូវផលវិបាកដែលកើតមានកន្លងមក នៅក្នុងរូបភាពនៃសិទ្ធិលើការបញ្ចាំ ដែលក្នុងនោះសិទ្ធិលើការបញ្ចាំកើតឡើង ដោយកូនបំណុល ឬ តតិយជនដែលបង្កើតសិទ្ធិលើការបញ្ចាំនោះ ប្រគល់វត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ ទៅឲ្យម្ចាស់សិទ្ធិលើការបញ្ចាំ[10] ហើយម្ចាស់សិទ្ធិលើការបញ្ចាំមិនអាចឲ្យអ្នកបង្កើតសិទ្ធិលើការបញ្ចាំនោះកាន់កាប់ដោយផ្ទាល់លើវត្ថុបញ្ចាំនោះបានឡើយ។[11] ក្នុងការអនុវត្តមួយដោយឡែក ការបង្កើតប្រាតិភោគដោយអនុប្បទានគឺមានលក្ខណៈងាយស្រួលដល់អ្នកបង្កើតដែលខាងក្រោមនេះ ខ្ញុំនឹងលើកឡើងនូវតម្រូវការចំពោះគូភាគី ដែលច្បាប់បានកំណត់ រួមមានល័ក្ខខ័ណ្ឌគ្រឹះ (១) ល័ក្ខខ័ណ្ឌទម្រង់ (២) និង ល័ក្ខខ័ណ្ឌតតាំង (៣) ដើម្បីឲ្យកិច្ចសន្យាដែលត្រូវបានបង្កើតនោះមានសុពលភាព ចំពោះគូភាគី ព្រមទាំង ចំពោះតតិយជនផងដែរ។

### ១. ល័ក្ខខ័ណ្ឌគ្រឹះ

រាល់ដំណើរការនៃការបង្កើតកិច្ចសន្យាទាំងឡាយតែងតម្រូវឲ្យគោរពនូវល័ក្ខខ័ណ្ឌគ្រឹះ ដែលជាកត្តាដ៏សំខាន់ឆ្ពោះទៅកាន់សុពលភាពនៃកិច្ចសន្យា។ ល័ក្ខខ័ណ្ឌដែលខ្វះមិនបានរបស់កិច្ចសន្យាប្រាតិភោគដោយអនុប្បទាន គឺតម្រូវឲ្យគោរពនូវគោលការណ៍សិទ្ធិសេរីភាពរបស់គូភាគី ពោលគឺបង្កើតដោយការព្រមព្រៀង (១.១) ហើយត្រូវឲ្យភាគីមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបង្កើតកិច្ចសន្យា (១.២) និងត្រូវមានកម្មវត្ថុសមស្របតាមច្បាប់ (១.៣)។

#### ១.១. ការព្រមព្រៀង

[10] ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ៨១៨។
[11] ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ៨១៩។

សិទ្ធិប្រាតិភោគដោយអនុប្បទាន ត្រូវបានបង្កើតឡើង ដោយការព្រមព្រៀងរវាងម្ចាស់បំណុល និង កូនបំណុល ឬ តតិយជន ដែលផ្ដល់ចលនវត្ថុសម្រាប់ប្រាតិភោគដោយអនុប្បទាន។[12] ការចែងបែបនេះចង់បានសេចក្ដីថា ប្រាតិភោគដោយអនុប្បទានត្រូវបានបង្កើតឡើង រវាងភាគីដោយការព្រមព្រៀង ពោលគឺសំដៅដល់គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន[13] ដែលបានលើកឡើងខាងលើ។ ឧទាហរណ៍ លោក ក ត្រូវការលុយ ១០លានរៀលជាបន្ទាន់ រួចលោកក៏សម្រេចចិត្តទៅនិយាយជាមួយលោក ខ ដើម្បីខ្ចីប្រាក់ ចំនួន ១០លានរៀល ដូចនេះ លោក ក បានសម្រេចបង្កើតកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន ដោយដាក់អនុប្បទានម៉ូតូរបស់ខ្លួនឲ្យលោក ខ ដើម្បីខ្ចីប្រាក់នោះ ប៉ុន្តែលោក ខ មិនព្រមឲ្យខ្ចីឡើយ។ ក្នុងករណីបានលើកឡើងនេះ លោក ក មិនអាចបង្ខិតបង្ខំទៅលើលោក ខ ដើម្បីធ្វើកិច្ចសន្យាឲ្យខ្លួនខ្ចីប្រាក់នោះទេ ព្រោះធ្វើដូច្នេះអាចបណ្ដាលឲ្យកើតមាននូវវិការៈនៃកិច្ចសន្យា។

កិច្ចសន្យាមានអនុភាពដោយសារសំណើ និង ស្វីការត្រូវគ្នា។[14] ការចែងបែបនេះបានស្ដែងឲ្យឃើញយ៉ាងច្បាស់ពីការព្រមព្រៀងគ្នារវាងគូភាគីនៃកិច្ចសន្យា ពោលគឺការបង្កើតកិច្ចសន្យាត្រូវឈរលើឆន្ទៈសេរីភាព ដោយមិនអាចមានការចាប់បង្ខំឡើយ។ គូភាគីម្ខាងត្រូវធ្វើសំណើសុំបង្កើតកិច្ចសន្យាដែលមានឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្ត ហើយគូភាគីម្ខាងទៀតត្រូវបង្ហាញឆន្ទៈទទួលយកសំណើរបស់ខ្លួននោះផងដែរ ទើបកិច្ចសន្យាអាចត្រូវបានបង្កើតឡើង។ វិការៈនឹងកើតមានឡើងប្រសិនបើមានប្រតិបត្តិការផ្ទុយពីការចែងនេះ។ អ្នកបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ដែលយោងតាមក្រមរដ្ឋប្បវេណីកម្ពុជាយើង វិការៈនៃកិច្ចសន្យារួមមាន ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការភាន់ច្រឡំ ដោយការឆបោក ឬ ការគម្រាមកំហែង ឬ ការបង្ហាញការមិនពិតរបស់ភាគីម្ខាងទៀត និង ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយអំពើឆ្លៀតឱកាសដោយមានគោលបំណងកេងយកចំណេញហួសហេតុ។[15]

យ៉ាងណាមិញ ឆ្លើយតបទៅនឹងការបកស្រាយខាងលើនេះ មិនមែនបានសេចក្ដីថានៅពេលមានវិការៈកើតមានឡើងក្នុងការបង្កើតកិច្ចសន្យា កិច្ចសន្យានោះនឹងត្រូវលុបចោលដោយឯកឯងនោះទេ។ នៅក្នុងប្រាតិភោគដោយអនុប្បទាន រាល់វិការៈដែលបានលើកឡើងខាងលើមិនមែនសុទ្ធសឹងតែអាចអះអាងបានទេ ពោលគឺត្រូវបង្ហាញនូវហេតុផលសមស្របមួយ។ ខ្ញុំលើកឡើងករណីកិច្ចសន្យាប្រាតិភោគដោយអនុប្បទានមួយ ដែលភាគីកូនបំណុលទាមទាឲ្យលុបចោល

12 ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ៨៨៩។
13 ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ៣។
14 ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ៣៣៦.១។
15 ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ៣៤៥, ចំណុច ក ខ និង គ។

កិច្ចសន្យា ដោយលើកយកហេតុផលវិការៈនៃកិច្ចសន្យា ព្រោះកម្មវត្ថុដែលខ្លួនបានដាក់អនុប្បទាន នោះមានតម្លៃច្រើនជាងបំណុលដែលខ្លួនខ្ចី។ ប៉ុន្តែយើងគួរដឹងថា ក្នុងការធ្វើប្រាតិភោគដោយ អនុប្បទាន អ្នកបង្កើតកិច្ចសន្យារមែងត្រូវដាក់អនុប្បទាននូវវត្ថុដែលមានតម្លៃច្រើនជាង ឬ ស្មើនឹង ចំនួនទឹកប្រាក់ដែលខ្លួនខ្ចី ហេតុនេះហើយ អ្នកបង្កើតកិច្ចសន្យាមិនអាចលើកឡើងថា កិច្ចសន្យា មានវិការៈព្រោះគូភាគីទទួលការចំណេញហួសហេតុឡើយ។ ដូចករណីដែលបានលើកឡើងនេះ ជាទូទៅ ម្ចាស់បំណុលគឺអាចទទួលសំណងត្រឹមតែចំនួនដែលជាកាតព្វកិច្ចរបស់កូនបំណុល ប៉ុណ្ណោះ បានសេចក្តីថា នៅពេលដែលអនុប្បទាយីបានបំពេញនូវតាវការលិករបស់ខ្លួនពេញលេញ អនុប្បទានិកត្រូវប្រគល់វត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យាវិញ ឬ បើករណីមិនសង អនុប្បទានិកត្រូវធ្វើ ការជូនដំណឹងទៅដល់អនុប្បទាយីធ្វើការលក់វត្ថុនោះ រួចដកយកតែចំនួនដែលជាកាតព្វកិច្ចត្រូវ បំពេញតែប៉ុណ្ណោះ។

ដោយឡែក ក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ជាក់អំពីអាជ្ញាយុកាល នៃការរំលត់សិទ្ធិលុបចោលកិច្ចសន្យា ដែលបញ្ញត្តិថា សកម្មភាពដែលអាចលុបចោលបាន មាន សុពលភាព រហូតដល់ពេលដែលអ្នកមានសិទ្ធិលុបចោល លុបចោលសកម្មភាពនោះ។[16] ក្នុងការ អនុវត្ត សិទ្ធិលុបចោលកិច្ចសន្យាអាចធ្វើឡើងក្នុងរយៈពេល ៣ (បី) ឆ្នាំ បន្ទាប់ពីបានដឹងអំពីវិការៈនៃ ការព្រមព្រៀង ឬ ក្នុងកំឡុងពេល ១០ (ដប់) ឆ្នាំ គិតចាប់តាំងពីកាលបរិច្ឆេទនៃការបង្កើត កិច្ចសន្យា។ ដូចនេះ បើកិច្ចសន្យាត្រូវបានរំលត់ នោះសិទ្ធិ និង កាតព្វកិច្ចក៏ត្រូវរលត់ដែរ តែក្នុង ករណីមិនអនុវត្តការលុបចោលកិច្ចសន្យា សិទ្ធិនៃការលុបចោលនោះនឹងត្រូវបានរលត់នៅពេលផុត អាជ្ញាយុកាល។[17]

ជារួម ក្នុងការបង្កើតកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន ទាមទារតម្រូវឲ្យមានជាចាំបាច់ នូវល័ក្ខខ័ណ្ឌដែលបានលើកឡើងនោះ គឺ "ការព្រមព្រៀង" ទើបការបង្កើតកិច្ចសន្យានោះមាន អនុភាពចំពោះមុខច្បាប់បាន។ ម្យ៉ាងវិញទៀត ការព្រមព្រៀងនោះត្រូវគោរពនូវគោលការណ៍ សេរីភាពរបស់គូភាគី ដោយគ្មានការបង្ខិតបង្ខំឡើយ បើពុំនោះទេនឹងអាចបណ្តាលឲ្យមានវិការៈក្នុង ការបង្កើតកិច្ចសន្យាបាន។ ករណីដែលបានលើកឡើងជាឧទាហរណ៍ខាងលើនេះ គឺដើម្បីញ៉ាំងឲ្យ ការបកស្រាយកាន់តែក្បោះក្បាយ។ ក្នុងស្ថានភាពជាក់ស្តែងនៅក្នុងសង្គមយើងនេះ ឃើញថាពុំសូវ មានករណីប្រាតិភោគដោយអនុប្បទានកើតឡើងទេ ហើយករណីដែលកើតឡើងក៏មិនបានប្រទះ ឃើញនូវបញ្ហាលំបាកពាក់ព័ន្ធទៅនឹងវិការៈនៃកិច្ចសន្យា ដែលឈានដល់ការលុបចោលនោះដែរ។

16 ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ៣៥៨។
17 ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ៣៦៣។

យ៉ាងណាមិញ យើងគួរសិក្សាទៅលើបញ្ហាទាំងអស់នេះដើម្បីធានាឲ្យបាននូវប្រសិទ្ធិភាពនៃការបង្កើតកិច្ចសន្យាប្រាតិភោគ ព្រមទាំងបង្កើននូវលទ្ធភាពក្នុងការដោះស្រាយរាល់បញ្ហាដែលអាចនឹងកើតមានឡើងបាន។

### ១.២. សមត្ថភាព

សមត្ថភាពក៏ជាធាតុផ្សំមួយដែលមានសារៈសំខាន់យ៉ាងខ្លាំង ក្នុងការបំពេញឲ្យបាននូវល័ក្ខខ័ណ្ឌគ្រឹះក្នុងការបង្កើតកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន។ យ៉ាងណាមិញ មុននឹងឈានទៅដល់ការយល់ដឹងអំពីសមត្ថភាព ដែលជាធាតុមួយនៃល័ក្ខខ័ណ្ឌគ្រឹះនេះ ការស្វែងយល់អំពីអត្ថន័យនៃពាក្យ "សមត្ថភាព" គឺមានសារៈសំខាន់ណាស់។ បើយោងទៅតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ ពាក្យថា "សមត្ថភាព" សំដៅទៅលើ លក្ខណៈសម្បត្តិរបស់បុគ្គល ដែលតម្រូវដោយច្បាប់រួមមាន លក្ខណៈសម្បត្តិ ដែលអាចក្លាយជាម្ចាស់សិទ្ធិ និងកាតព្វកិច្ច ឬ លក្ខណៈសម្បត្តិ ដែលអាចយល់ដឹង និងអាចវិនិច្ឆ័យបានអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ឬ ជាលក្ខណៈសម្បត្តិ ដែលអាចធ្វើឲ្យសកម្មភាពរបស់ខ្លួន មានអានុភាពតាមផ្លូវច្បាប់។[18] អត្ថន័យដែលលើកឡើងខាងលើនេះ បើនិយាយឲ្យងាយស្រួលយល់ គឺសំដៅដល់សមត្ថភាពទទួលបានសិទ្ធិ សមត្ថភាពខាងឆន្ទៈ និង សមត្ថភាពក្នុងការធ្វើសកម្មភាព។

ក្នុងការបង្កើតកិច្ចសន្យា ជនដែលត្រូវបានកម្រិតសមត្ថភាព សំដៅទៅលើអនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និង ជននៅក្រោមហិតូបត្ថម្ភ។[19] ច្បាប់ធ្វើកម្រិតសិទ្ធិទៅលើជនទាំងនេះ ដោយហេតុថា ជនទាំងឡាយដែលបានលើកឡើងខាងលើនេះ មិនអាចធ្វើការថ្លឹងថ្លែង ចេះគិតត្រិះរិះ ពិចារណាអំពីលទ្ធផលដែលកើតចេញពីសកម្មភាពរបស់ខ្លួន ដែលនេះមិនសំដៅទៅលើសិទ្ធិសេរីភាពក្នុងការធ្វើសកម្មភាពក្នុងការរស់នៅប្រចាំថ្ងៃដោយឯករាជ្យឡើយ។ ផ្ទុយទៅវិញ ក្នុងសកម្មភាពដែលពាក់ព័ន្ធទៅនឹងការធ្វើកិច្ចសន្យាជាដើម គឺរមែងតម្រូវឲ្យជននោះអាចធ្វើសកម្មភាពបានលុះត្រាតែមានការយល់ព្រមពីអ្នកតំណាងដែលច្បាប់កំណត់ ឬ ហិតូបត្ថម្ភកៈ។ មិនតែប៉ុណ្ណោះ ចំពោះអនីតិជនដែលទទួលបានអត្តាធិនភាព ដែលជាសញ្ញាណមួយបញ្ជាប់អំពីនីតិភាពរបស់ជននោះ គឺច្បាប់បានទទួលនូវសកម្មភាពរបស់ជននោះចាត់ទុកជាស្របច្បាប់។ ហេតុដូចបានបកស្រាយនេះ បើលើកយកករណីកិច្ចសន្យាប្រាតិភោគដោយអនុប្បទានមកបង្ហាញ កិច្ចសន្យា

---

[18] គណកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, សន្ទានុក្រមផ្នែករដ្ឋប្បវេណី, បោះពុម្ពដោយទីស្តីការគណៈរដ្ឋមន្ត្រី, ឆ្នាំ ២០០៧ (ហៅថា សទ្ទានុក្រមផ្នែករដ្ឋប្បវេណី), ទំព័រ ២១ និង ២២។

[19] ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ១៦។

ទាំងឡាយណា ដែលត្រូវបានបង្កើតឡើងដោយជនមិនមានសមត្ថភាពគ្រប់គ្រាន់កំណត់ក្នុងច្បាប់ នោះកិច្ចសន្យាប្រាតិភោគដោយអនុប្បទាននោះនឹងអាចត្រូវបានលុបចោលល្ហិកណាសមីខ្លួន អ្នកតំណាងដោយច្បាប់កំណត់ ឬ ហិតូបត្ថម្ភកៈធ្វើការទាមទារឲ្យលុបចោល។ ផ្ទុយទៅវិញ កិច្ចសន្យានោះនឹងនៅតែមានសុពលភាពដដែល ប្រសិនបើមិនមានជនណាមកទាមទារឲ្យលុបចោលក្នុងកំឡុងពេលសុពលភាពនៃកិច្ចសន្យា និងមិនផុតអាជ្ញាយុកាលនៃសិទ្ធិនោះ។

សរុបមកវិញ សមត្ថភាព ដែលជាល័ក្ខខ័ណ្ឌគ្រឹះមួយទៀតក្នុងការបង្កើតពិតជាមានសារៈសំខាន់ខ្លាំងណាស់ ពោលគឺជាចំណុចដែលធ្វើឲ្យឈានទៅដល់សុពលភាពនៃកិច្ចសន្យានោះ។ ទោះបីជនដែលត្រូវបានកម្រិតសមត្ថភាពអាចធ្វើកិច្ចសន្យាបានក៏ដោយ ក៏គួរតែជៀសឲ្យបាននូវករណីនេះ ព្រោះថាដរាបណាមានជនទាមទារឲ្យលុបចោលកិច្ចសន្យា កិច្ចសន្យានោះនឹងត្រូវបានរំលាយ។

### ១.៣. កម្មវត្ថុ

ដូចគ្នាទៅនឹងចំណុចពីរខាងលើដែលរួមមានការព្រមព្រៀង និង សមត្ថភាព កម្មវត្ថុក៏ជាល័ក្ខខ័ណ្ឌគ្រឹះមួយក្នុងការបង្កើតកិច្ចសន្យាប្រាតិភោគដោយអនុប្បទានដែរ។ ដូចមានចែងក្នុងក្រមរដ្ឋប្បវេណីយើង ប្រាតិភោគដោយអនុប្បទាន សំដៅទៅលើការណ៍ដែលកូនបំណុល ឬ តតិយជនធ្វើអនុប្បទាននូវចលវត្ថុរបស់ខ្លួនជាកំណត់ ទៅឲ្យម្ចាស់បំណុល ដើម្បីធានាកាតព្វកិច្ច។[20] យើងឃើញថា ច្បាប់បានកំណត់យ៉ាងច្បាស់ ដែលតម្រូវឲ្យកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទានគឺ ចលនវត្ថុ។ ពាក្យថា "ចលនវត្ថុ" គឺសំដៅទៅដល់វត្ថុក្រៅពីអចលនវត្ថុ ពោលគឺសំដៅទៅលើវត្ថុ ឬ ទំនិញទាំងឡាយណាដែលអាចផ្លាស់ប្តូរទីកន្លែង និងបំលាស់ទីបាន ឬសំដៅលើវត្ថុក្រៅពីដំណាំ ដីធ្លី អាគារ រុក្ខជាតិជាដើម។ ដូចនេះវត្ថុដែលជាចលនវត្ថុដែលអាចដាក់ធានាក្នុងការប្រាតិភោគដោយអនុប្បទានបានរួមមានដូចជា ទំនិញសារពើភណ្ឌ កសិផល ទំនិញប្រើប្រាស់ ឧបករណ៍ និងចលនវត្ថុតាំងភ្ជាប់ជាដើម។ បើយោងតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ដែលជាច្បាប់ពិសេសបំពេញបន្ថែមលើក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០០៧ ទំនិញសារពើភណ្ឌ គឺជាទំនិញដែលបុគ្គលកាន់កាប់សម្រាប់លក់ ជួល ឬ ជាវត្ថុធាតុដើម គម្រោងដែលកំពុងដំណើរការ សម្ភារៈដែលប្រើប្រាស់ក្នុងអាជីវកម្ម[21] រួមមានដូចជា ម៉ាស៊ីនកាត់ដេរ ដែលកំពុងដំណើរការក្នុងរោងចក្រ ម៉ាស៊ីនកុំព្យូទ័រដែលដាក់លក់ក្នុងហាងជាដើម។ ច្បាប់ដដែលក៏បានកំណត់ពាក្យកសិផលថាជាទំនិញរបស់កូន

20 ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ៨៨៨

21 ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ឆ្នាំ ២០០៧, មាត្រា ៣។

បំណុល ដែលបានពីមុខរបរកសិកម្ម រួមមានផលដំណាំ សត្វចិញ្ចឹមជាដើម។ រីឯទំនិញប្រើប្រាស់ គឺជាទំនិញដែលបានប្រើប្រាស់ ឬទិញសម្រាប់ប្រើប្រាស់ជាចំបងសម្រាប់គោលបំណងផ្ទាល់ខ្លួន ឬសម្រាប់គ្រួសារ ដែលមានតែយានយន្តមានលេខស៊េរីទើបអាចជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគបាន។ ចំពោះឧបករណ៍វិញ មានន័យថា ទំនិញលើកលែងតែកសិផល សារពើភណ្ឌ ទំនិញប្រើប្រាស់ ឬយានយន្តមានលេខស៊េរី ដូចជាម៉ាស៊ីនថតចំលងដែលប្រើប្រាស់ក្នុងការិយាល័យមួយ ឬ ឡរបស់ហាងនំប៉័ង។ និងពាក្យថា ចលនវត្ថុតាំងភ្ជាប់ គឺសំដៅលើទំនិញដែលបានភ្ជាប់ទៅនឹងអចលនវត្ថុ ឬមានគោលបំណងតាំងភ្ជាប់ទៅនឹងអចលនវត្ថុ ដែលនាំឲ្យសិទ្ធិប្រត្យក្សកើតឡើងតាមច្បាប់ភូមិបាលជាធរមាន ដែលវត្ថុនោះអាចជាម៉ាស៊ីនត្រជាក់ដែលភ្ជាប់ក្នុងអាគារជាដើម។

ដោយឡែក ចលនវត្ថុប្រភេទម្យ៉ាងទៀតបានចែងនៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ថា ចលនវត្ថុច្រើន ដែលត្រូវបានកំណត់ទំហំតាមមាត្រដ្ឋាន ដូចជាប្រភេទ ឬ កន្លែងស្ថិតនៅនៃចលនវត្ថុ អាចយកមកធ្វើជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ដោយចាត់ទុកជាចលនវត្ថុផ្តុំគ្នាតែមួយបាន ទោះបីជាចលនវត្ថុនីមួយៗដែលផ្តុំគ្នានោះ មានការប្រែប្រួលក៏ដោយ។[22] កថាខណ្ឌនេះត្រូវបានចែងឡើងដើម្បីជៀសវាងបញ្ហាដែលនឹងកើតមានឡើង ដែលសំដៅលើចលនវត្ថុច្រើនដែលស្ថិតនៅកន្លែងតែមួយ ឬ ដែលភាគច្រើនមានប្រភេទដូចគ្នា រួមមានដូចជាវត្ថុ ឬទំនិញនៅក្នុងហាងលក់ទំនិញមួយ ឬ អាចជាសត្វទាច្រើនក្បាលនៅក្នុងកសិដ្ឋានចិញ្ចឹមទាមួយជាដើម។ នៅក្នុងប្រាតិភោគដោយអនុប្បទាន ការដាក់ប្រាតិភោគចលនវត្ថុផ្តុំគ្នានេះ គឺមានលក្ខណៈងាយស្រួល ជាពិសេសសម្រាប់កូនបំណុលដែលជាអាជីវករ ឬ ពាណិជ្ជករ ដែលចាំបាច់ត្រូវទទួលផលពីកម្មវត្ថុដែលខ្លួនដាក់ប្រាតិភោគក្នុងការស្វែងរកចំណូល។ ប្រាតិភោគដោយអនុប្បទានមានលក្ខណៈល្អត្រង់ថា កូនបំណុលអាចនឹងមានលទ្ធភាព ក្នុងការធ្វើការសងបំណុលឆាប់រហ័សជាងប្រាតិភោគនៃប្រភេទផ្សេងៗ ដូចជាការបញ្ចាំ ឬ ហ៊ីប៉ូតែក ដោយហេតុថាក្នុងរឿងប្រាតិភោគដោយអនុប្បទាន កូនបំណុលមានសិទ្ធិរក្សាទុកនូវវត្ថុដែលជាកម្មវត្ថុប្រាតិភោគ ដើម្បីធ្វើការទទួលផលពីវត្ថុទាំងនោះបាន ដោយទាមទារតែធ្វើការផ្ទេរនូវសិទ្ធិកាន់កាប់ក្នុងរូបភាពណាមួយតែប៉ុណ្ណោះ។

ម្យ៉ាងវិញទៀត ចំពោះកម្មវត្ថុនេះ បើយោងទៅតាមមាត្រា ៧៦៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ បានចែងថា សិទ្ធិប្រាតិភោគប្រត្យក្សមិនអាចយកវត្ថុ ឬ សិទ្ធិណាដែលមិនអាចធ្វើអនុប្បទានបាន មកធ្វើជាកម្មវត្ថុបានទេ។ អត្ថន័យនៃសិទ្ធិប្រាតិភោគមានត្រង់ចំណុចថា ក្នុងករណីដែលកាតព្វកិច្ចមិនត្រូវបានសងទេ វត្ថុ ឬ សិទ្ធិដែលជាកម្មវត្ថុនៃសិទ្ធិនោះ ត្រូវបានចាត់ចែងប្តូរជាប្រាក់ ហើយម្ចាស់សិទ្ធិនៃប្រាតិភោគនឹងទទួលការសងពីប្រាក់នោះដោយមានអាទិភាព[23] ហេតុដូច្នេះហើយ ប្រសិនបើកម្មវត្ថុដែលធ្វើការយកមកដាក់ប្រាតិភោគពុំមានតម្លៃសេដ្ឋកិច្ចនោះទេ វាហាក់

22 ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ៨៤៨.២។

23 សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០១០ ភាគ ៤៖ គន្លឹះទី ៦, ទំព័រ ៣។

បីដូចជាម្ចាស់បំណុលពុំបានទទួលនូវវត្ថុដែលអាចធ្វើការប្តូរជាប្រាក់ដើម្បីធានាបំណុលខ្លួនដូច្នេះដែរ។ លើសពីនេះទៅទៀត ក្នុងការអនុវត្តកន្លងមក គេតែងទទួលប្រាតិភោគណាដែលតម្លៃនៃកម្មវត្ថុនោះលើសពីចំនួនបំណុលរបស់ខ្លួន ធ្វើដូច្នេះ ការធានាការសងមានភាគរយខ្ពស់។

សរុបមកវិញ ល័ក្ខខ័ណ្ឌគ្រឹះ ដែលរួមមាន ការព្រមព្រៀងរវាងភាគីសងខាង សមត្ថភាព និង កម្មវត្ថុគឺពិតជាមានសារៈសំខាន់ និង ចាំបាច់ក្នុងការបង្កើតកិច្ចសន្យាប្រាតិភោគមួយដែលមានសុពលភាព ហើយដែលត្រូវបានទទួលស្គាល់ដោយច្បាប់។ អវត្តមាននូវល័ក្ខខ័ណ្ឌមួយក្នុងចំណោមល័ក្ខខ័ណ្ឌទាំងបីនេះនឹងអាចបណ្តាលឲ្យកិច្ចសន្យាឈានទៅដល់ការរំលាយ ប្រសិនជាអ្នកមានសិទ្ធិទាមទារលុបចោលធ្វើការទាមទារឱ្យលុបចោលកិច្ចសន្យាដែលមានវិការៈនេះ។ ហេតុដូច្នេះហើយ វាពិតជាចំណុចដែលខ្វះពុំបានដែលអ្នកទាំងឡាយណា មានបំណងចងបង្កើតកិច្ចសន្យាប្រាតិភោគដោយអនុប្បទានគួរគប្បីយល់ដឹងឲ្យបានច្បាស់លាស់មុននឹងអនុវត្តកិច្ចប្រតិបត្តិការនេះ។

### ២. ល័ក្ខខ័ណ្ឌទម្រង់

ក្រៅពីល័ក្ខខ័ណ្ឌគ្រឹះ ល័ក្ខខ័ណ្ឌទម្រង់ក៏ជាល័ក្ខខ័ណ្ឌចាំបាច់ក្នុងការបង្កើតកិច្ចសន្យាប្រាតិភោគដោយអនុប្បទានដែរ។ ក្នុងចំណុចនេះ ការព្រមព្រៀងគឺជាល័ក្ខខ័ណ្ឌទម្រង់ក្នុងការបង្កើតប្រាតិភោគដោយអនុប្បទាន ដូចដែលមានចែងក្នុងក្រមរដ្ឋប្បវេណីថា សិទ្ធិប្រាតិភោគដោយអនុប្បទាន ត្រូវបានបង្កើតឡើង ដោយការព្រមព្រៀងរវាងម្ចាស់បំណុល និង កូនបំណុល ឬ តតិយជន ដែលផ្តល់ចលនវត្ថុសម្រាប់ប្រាតិភោគដោយអនុប្បទាន។[24] យោងទៅតាមការចែងនេះ ច្បាប់បានទុកលទ្ធភាពឲ្យភាគីទាំងសងខាងធ្វើការព្រមព្រៀងដោយសេរីពោលគឺអាចធ្វើការចរចារទៅលើការប្រគល់វត្ថុដែលជាកម្មវត្ថុជាដើម។

ល័ក្ខខ័ណ្ឌទម្រង់ពុំសូវមានលក្ខណៈស្មុគស្មាញឡើយ ព្រោះថាច្បាប់បានគោរពនូវគោលការណ៍សេរីភាពនៃឆន្ទៈរបស់គូភាគី ដោយបើកសិទ្ធិឲ្យធ្វើការបញ្ចេញនូវមតិ និង ល័ក្ខខ័ណ្ឌដែលខ្លួនចង់បាន។ ទោះជាយ៉ាងណាក៏ដោយ ក្នុងការអនុវត្តជាក់ស្តែងសព្វថ្ងៃនេះ ភាគីម្ចាស់បំណុល តែងចរចារទាមទារឲ្យមានការប្រគល់វត្ថុដែលជាកម្មវត្ថុនៃការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ធ្វើដូច្នេះទើបខ្លួនអាចទុកចិត្តថានឹងទទួលបានសំណងវិញទាន់ពេលវេលា និង ឆាប់រហ័ស។ មួយវិញទៀត យើងក៏មិនបានប្រទះឃើញនូវបញ្ញត្តិណាមួយដែលចែងអំពីសិទ្ធិក្នុងការ

[24] ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា៨៨៩។

មិនប្រគល់វត្ថុដែលជាកម្មវត្ថុផងដែរ ទាំងក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ក្តី ទាំងប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្តី។ អ្វីដែលគួរតែកត់សម្គាល់នោះគឺ ប្រជាពលរដ្ឋពុំបានជ្រៀបនូវបញ្ញត្តិនៃប្រាតិភោគដោយអនុប្បទានដែរ ដែលធ្វើឲ្យការអនុវត្តទៅតាមសិទ្ធិលើការបញ្ចាំនូវតែបន្តកើតមានឡើង។

### ៣. លក្ខខណ្ឌតតាំង

លក្ខខណ្ឌតតាំង គឺជាលក្ខខណ្ឌមួយដ៏មានសារៈសំខាន់ក្នុងការបង្កើតកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន ដែលលក្ខខណ្ឌនេះអាចឲ្យម្ចាស់បំណុលមានសិទ្ធិពេញលេញក្នុងការអះអាងចំពោះតតិយជនដទៃបានថាខ្លួនពិតជាមានសិទ្ធិទៅលើបំណុលជាងជនដទៃនោះ។ ដូចមានចែងក្នុងក្រមរដ្ឋប្បវេណីកម្ពុជា ស្តីពីអានុភាពតតាំងនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ពុំអាចតតាំងសិទ្ធិប្រាតិភោគដោយអនុប្បទាននោះ ចំពោះតតិយជនក្រៅពីអ្នកបង្កើតបានឡើយ បើមិនបានទទួលការផ្ទេរការកាន់កាប់វត្ថុដែលជាកម្មវត្ថុ ដោយយោងតាមបញ្ញត្តិនៃមាត្រា ២២៩ (ការផ្ទេរការកាន់កាប់) នៃក្រមនេះ។[25] ដូចបានលើកឡើងនេះ អានុភាពនៃការតតាំងអាចកើតមានបាននៅពេលមានការផ្ទេរការកាន់កាប់ ដែលមានចែងនៅក្នុងមាត្រា ២២៩ ប៉ុន្តែចំណុចនៃការផ្ទេរការកាន់កាប់នេះ ខ្ញុំនឹងធ្វើការអត្ថាធិប្បាយនៅក្នុងចំណុចបន្ទាប់។ ដោយឡែក លក្ខខណ្ឌតតាំងនេះផងដែរ ជាលក្ខខណ្ឌទាក់ទងនឹងការផ្សព្វផ្សាយជាសាធារណៈអំពីការបង្កើត ការផ្ទេរ ឬ ការកែប្រែនូវសិទ្ធិប្រត្យក្សដើម្បីជាប្រយោជន៍សម្រាប់សុវត្ថិភាពគតិយុត្តក្នុងការជួញដូរ។[26] ដោយហេតុថា ក្នុងការរស់នៅប្រចាំថ្ងៃ កិច្ចសន្យាកើតមានឡើងនៅស្ទើរតែជុំវិញខ្លួនដែលតម្រូវឲ្យគូភាគីមានការព្រមព្រៀងគ្នាទៅវិញទៅមកលើលក្ខខណ្ឌទាំងឡាយ ដូចនេះហើយការតតាំងចំពោះតតិយជន សំដៅទៅដល់ករណីដែលមានការទាមទារ ឬ សកម្មភាពផ្សេងៗទៀតដែលកើតមានឡើងលើទ្រព្យដែលបានត្រូវដាក់ប្រាតិភោគ បានសេចក្តីថាម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានអាចប្រើសិទ្ធិប្រត្យក្សដែលខ្លួនមាននោះ មកអះអាងក្នុងការការពារសិទ្ធិរបស់ខ្លួនបានដើម្បីធានាឲ្យបានថាខ្លួននឹងនៅតែទទួលបានសំណង់ដដែល។ ក្នុងករណីជាក់ស្តែង យើងមិនអាចប្រាកដបានថាកូនបំណុលជំពាក់ម្ចាស់បំណុលតែម្នាក់នោះទេ តែគឺអាចមានករណីដែលថាកូនបំណុលប្រហែលជាមានម្ចាស់បំណុលច្រើន ដែលនៅជាប់ជំពាក់ជំពិននឹងបំណុល។ ហេតុដូចនេះ

---

25 ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ៨៩០។

26 ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ១, ខែមេសា ឆ្នាំ២០១៣។

ហើយទើបនៅក្នុងការបង្កើតប្រាតិភោគដោយអនុប្បទាន លក្ខខ័ណ្ឌតតាំងពិតជាសំខាន់ណាស់ ព្រោះម្ចាស់បំណុលណាដែលទទួលបានការផ្ទេរការកាន់កាប់នឹងមានលទ្ធភាពក្នុងការតតាំងជាមួយនឹងតតិយជន ដែលភាគច្រើនគឺសំដៅលើម្ចាស់បំណុលផ្សេងៗ។

### កថាភាគទី ២៖ ការផ្ទេរការកាន់កាប់

ការកាន់កាប់ សំដៅទៅលើការក្តាប់ទុកវត្ថុ ហើយការក្តាប់ទុកវត្ថុសំដៅទៅលើការគ្រប់គ្រងលើរូបវត្ថុ តាមការជាក់ស្តែង ទោះដោយចំពោះក្តី ឬ ដោយប្រយោលក្តី។[27] នៅក្នុងការផ្ទេរការកាន់កាប់ យើងអាចធ្វើបានតាមរយៈប្រភេទនៃការផ្ទេរទាំង ៤ ដែលក្នុងនោះរួមមាន "ការប្រគល់ដោយជាក់ស្តែង" "ការប្តូរលក្ខណៈនៃការកាន់កាប់" "ការប្រគល់ដោយសង្ខេប" និង "ការផ្ទេរការកាន់កាប់ដោយបញ្ជា"។ ក្រមរដ្ឋប្បវេណីកម្ពុជាបានបញ្ញត្តិផងដែរថា អនុប្បទាននូវសិទ្ធិប្រត្យក្សលើចលនវត្ថុទៅបុគ្គលណាមួយ មិនអាចតតាំងនឹងតតិយជនបានឡើយ បើពុំបានផ្ទេរការកាន់កាប់ចលនវត្ថុទៅបុគ្គលនោះទេ។[28] យើងឃើញថាការកែប្រែនូវសិទ្ធិប្រត្យក្សលើចលនវត្ថុដែលត្រូវបានទទួលស្គាល់គឺមានតែ ៤ ប្រភេទដែលនឹងត្រូវធ្វើការពន្យល់នៅខាងក្រោម៖

#### ១. ការប្រគល់ដោយជាក់ស្តែង

បើយោងទៅតាមមាត្រា ២២៩ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ ២០០៧ "ការប្រគល់ដោយជាក់ស្តែង" គឺជាការប្រគល់ដោយផ្ទាល់ដៃពីអ្នកកាន់កាប់ទៅអ្នកទទួលការកាន់កាប់តាមការជាក់ស្តែង។ ចំណុចនេះបានសេចក្តីថា មុនការផ្ទេរ វត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគគឺស្ថិតនៅក្នុងការកាន់កាប់របស់អនុប្បទាយី ហើយអនុប្បទានិកជាអ្នកកាន់កាប់វត្ថុនោះវិញក្រោយការផ្ទេរ ដោយឈរក្រោមល័ក្ខខ័ណ្ឌនៃឆន្ទៈព្រមព្រៀងផ្ទេរការកាន់កាប់ និង ការផ្ទេរការកាន់កាប់ដោយផ្ទាល់។ (អនុប្បទាយី -> អនុប្បទានិក)

#### ២. ការប្តូរលក្ខណៈនៃការកាន់កាប់

មាត្រា ២២៩ ដដែល កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីកម្ពុជា ក៏មានចែងអំពីការប្តូរលក្ខណៈនៃការកាន់កាប់ផងដែរ។ ត្រង់ចំណុចនេះ "ការប្តូរលក្ខណៈនៃការកាន់កាប់" គឺការកាន់កាប់អាចត្រូវបានផ្ទេរ ដោយការព្រមព្រៀងគ្នារវាងគូភាគីតែប៉ុណ្ណោះ ដោយគ្មានការប្រគល់វត្ថុនោះដោយជាក់ស្តែងទេ។ ក្នុងករណីនេះ អនុប្បទានិកនៃការកាន់កាប់ត្រូវទទួលការកាន់កាប់ដោយប្រយោល តាមរយៈអនុប្បទាយី។ ល័ក្ខខ័ណ្ឌនៃការប្តូរលក្ខណៈនៃការកាន់កាប់នេះគឺស្ថិតត្រង់ថា

27 ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ២២៧។
28 ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ១៣៤។

គូភាគីទាំងពីរគ្រាន់តែបង្ហាញឆន្ទៈក្នុងការផ្ទេរ ដោយវត្ថុជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទានស្ថិតក្នុងការកាន់កាប់របស់អនុប្បទាយីទាំងមុន និង ក្រោយការផ្ទេរសិទ្ធកាន់កាប់។ ករណីនេះនិយមកើតមានឡើងនៅក្នុងប្រតិបត្តិការប្រាតិភោគដោយអនុប្បទានលើចលនវត្ថុផ្គុំគ្នា ដោយសារថាវត្ថុទាំងនោះជាតម្រូវការចាំបាច់របស់អ្នកបង្កើត ហើយមិនអាចប្រគល់ទៅឲ្យម្ចាស់សិទ្ធិកាន់កាបដោយផ្ទាល់ឡើយ។ គួរបញ្ជាក់ផងដែរថា ចលនវត្ថុផ្គុំគ្នា គឺចលនវត្ថុច្រើន ដែលត្រូវបានកំណត់ទំហំតាមមាត្រដ្ឋាន ដូចជាប្រភេទ ឬកន្លែងស្ថិតនៅនៃចលនវត្ថុ។ (អនុប្បទាយី -> អនុប្បទាយី)

### ៣. ការប្រគល់ដោយសង្ខេប

ចំពោះករណីការប្រគល់ដោយសង្ខេបនេះ ក្នុងមាត្រា ២២៩ កថាខណ្ឌទី៣ បានចែងថា បើអ្នកដែលនឹងទទួលអនុប្បទាននូវការកាន់កាប់ ក្តាប់ទុកវត្ថុកាន់កាប់ដោយចំពោះ តាមការជាក់ស្តែង ការកាន់កាប់អាចត្រូវបានផ្ទេរ ដោយការព្រមព្រៀងគ្នារវាងគូភាគីតែប៉ុណ្ណោះ។ ដោយសារហេតុនេះ អនុប្បទាយីនៃការកាន់កាប់ ត្រូវបាត់បង់ការកាន់កាប់ដោយប្រយោលដែលខ្លួនធ្លាប់មាន តាមរយៈអ្នកក្តាប់ទុកវត្ថុកាន់កាប់ ការផ្ទេរការកាន់កាប់បែបនេះ ហៅថា ការប្រគល់ដោយសង្ខេប។ បើមើលលើការផ្ទេរការកាន់កាប់ប្រភេទនេះវិញគឺអនុប្បទានិកកាន់កាប់រួចជាស្រេច ពោលគឺមុន និង ក្រោយការផ្ទេរ វត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគគឺស្ថិតនៅក្នុងការកាន់កាប់របស់អនុប្បទានិកតែម្តង។ (អនុប្បទានិក -> អនុប្បទានិក)

### ៤. ការផ្ទេរការកាន់កាប់ដោយបញ្ជា

នៅក្នុងការផ្ទេរការកាន់កាប់ដោយបញ្ជា ក្នុងមាត្រា ២២៩ កថាខណ្ឌទី៤ បានចែងថា ការផ្ទេររវាងអ្នកកាន់កាប់ដោយប្រយោលតាមរយៈអ្នកដទៃ ជាមួយនឹងតតិយជន។ អ្នកកាន់កាប់ដោយប្រយោលតាមរយៈអ្នកដទៃអាចផ្ទេរការកាន់កាប់ទៅឲ្យតតិយជនបាន ដោយការព្រមព្រៀងជាមួយតតិយជន និង ដោយការជូនដំណឹងអំពីហេតុនោះ ទៅឲ្យអ្នកកាន់កាប់ដោយចំពោះ។ ការផ្ទេរបែបនេះបានសេចក្តីថា គូភាគីមានឆន្ទៈព្រមព្រៀងផ្ទេរឲ្យតតិយជនណាម្នាក់កាន់កាប់ ដោយវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគនោះ ស្ថិតក្នុងការកាន់កាប់របស់តតិយជនដែលទទួលបញ្ជាឲ្យកាន់កាប់។ (អនុប្បទាយី -> តតិយជនដែលទទួលបញ្ជា)

មាត្រា ២២៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ដែលបានយោងឡើងនៅខាងលើនេះទាក់ទិននឹងការផ្ទេរការកាន់កាប់គឺបានចែងអំពីវិធី ៤ យ៉ាង ដែលសុទ្ធសឹងតែជាល័ក្ខខ័ណ្ឌតតាំងនៃការ

ផ្លាស់ប្តូរសិទ្ធិប្រត្យក្សលើចលនវត្ថុ។ ហេតុដូចនេះហើយ ក្នុងការបង្កើតកិច្ចសន្យាប្រាតិភោគដោយអនុប្បទានគឺរមែងត្រូវមានការទទួលបានការផ្ទេរការកាន់កាប់។ សរុបមកវិញ តាមរយៈការទទួលការកាន់កាប់ដែលបានពន្យល់ខាងលើ នាំឲ្យម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានអាចប្រើប្រាស់សិទ្ធិប្រត្យក្សដែលខ្លួនមាន ដើម្បីតតាំងនឹងតតិយជន ឬ ធ្វើសកម្មភាពផ្សេងៗកើតឡើងលើទ្រព្យដែលបានដាក់ធានា។

# ជំពូកទី ២
# អានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

អានុភាពត្រូវកើតមានតំណាលគ្នានៅពេលមានការបង្កើតកិច្ចសន្យា ហើយអានុភាពនេះ គឺជាចំណងមួយដ៏សំខាន់ដែលចងភ្ជាប់ទំនាក់ទំនងគតិយុត្តរវាងគូភាគីកិច្ចសន្យា។ ដូចគ្នាផង ដែរក្នុងកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន មាត្រា ៧៧១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បាន បញ្ញត្តិអំពី អវិភាគភាពនៃសិទ្ធិប្រាតិភោគប្រត្យក្សថា អានុភាពនៃសិទ្ធិប្រាតិភោគប្រត្យក្សត្រូវមាន លើវត្ថុ ឬ សិទ្ធិដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគប្រត្យក្សទាំងអស់ រហូតដល់ពេលដែលម្ចាស់សិទ្ធិ ប្រាតិភោគបានទទួលសំណងនៃសិទ្ធិលើបំណុលទាំងអស់វិញ។ ដោយឡែក បើក្រលែកមក មើលលើអានុភាពនៃប្រាតិភោគដោយអនុប្បទានវិញ ជាដំបូង តើពាក្យ "អានុភាព" មានន័យ យ៉ាងណាក្នុងបរិបទច្បាប់? តាមច្បាប់ ពាក្យនេះសំដៅទៅលើផលគតិយុត្ត ដែលកើតចេញពី លិខិតគតិយុត្ត ដូចជា កិច្ចសន្យា ច្បាប់ សេចក្តីសម្រេចរបស់តុលាការ សេចក្តីសម្រេចរបស់ រដ្ឋបាល។[29] ហេតុដូច្នេះ មាត្រាដែលបានលើកឡើងខាងលើអម្បាលមិញនេះ បញ្ជាក់យ៉ាងច្បាស់ ពីអានុភាពដែលជាផលគតិយុត្តទទួលបានតាមផ្លូវច្បាប់ចំពោះម្ចាស់សិទ្ធិ តាមរយៈអត្ថិភាពនៃ សិទ្ធិប្រាតិភោគដោយអនុប្បទាន ពោលគឺតាមរយៈការបង្កើតនូវកិច្ចសន្យាដែលបំពេញនូវ ល័ក្ខខ័ណ្ឌសុពលភាពនេះឯង។ ដោយអានុភាពនៅក្នុងប្រាតិភោគដោយអនុប្បទានមានភាព ទូលំទូលាយ ខ្ញុំសុំធ្វើការបែងចែកការពន្យល់ជាប្លង់ដែលជាដំបូងនឹងធ្វើការបកស្រាយទៅលើ អានុភាពចំបង (ផ្នែកទី១) និង អានុភាពដោយឡែក (ផ្នែកទី២)។

## ផ្នែកទី១៖ អានុភាពចំបង

ដូចគ្នាទៅនឹងការដាក់ប្រាតិភោគតាមរូបភាពផ្សេងៗពីមុន ជាអាទិ៍ការបញ្ចាំ អ៊ីប៉ូតែក ជា ដើម ក្រមរដ្ឋប្បវេណីបានបញ្ញត្តិប្រាតិភោគមួយផ្សេងទៀតគឺ ប្រាតិភោគដោយអនុប្បទាន ដែល ប្រភេទប្រាតិភោគនេះក៏បង្កើតឲ្យមាននូវអានុភាពដែរ។ ក្នុងការបង្កើតកិច្ចសន្យាប្រាតិភោគដោយ អនុប្បទាននេះ វាបានបង្កើតឲ្យមាននូវអានុភាពចំពោះវត្ថុ (កថាភាគទី១) ចំពោះផលដែលកើត ចេញពីវត្ថុដែលជាកម្មវត្ថុ (កថាភាគទី២) និង ចំពោះបំណុល (កថាភាគទី៣)។

### កថាភាគទី ១៖ អានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទានចំពោះវត្ថុ

ដូចដែលបានលើកឡើងកន្លងមក ប្រាតិភោគដោយអនុប្បទាន គឺការណ៍ដែលកូនបំណុល ឬ តតិយជនធ្វើអនុប្បទាននូវចលនវត្ថុរបស់ខ្លួនជាកំណត់ ទៅឱ្យម្ចាស់បំណុល ដើម្បីធានា

---

29 សន្ទានុក្រមផ្នែករដ្ឋប្បវេណី ឆ្នាំ ២០០៧, ទំព័រ ២៨ ។

កាតព្វកិច្ច។ ចលនវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគលើកឡើងខាងលើនេះ បានបង្កើតឲ្យមាននូវអានុភាពចំពោះម្ចាស់សិទ្ធិ។ ដូចនេះ តើអានុភាពនេះបានផ្ដល់នូវទំហំនៃសិទ្ធិត្រឹមកម្រិតណា យើងនឹងធ្វើការសិក្សាបន្តនៅក្នុងចំណុចខាងក្រោម។

### ១. ទំហំនៃសិទ្ធិដែលមានអានុភាព

សិទ្ធិប្រាតិភោគដោយអនុប្បទាន ត្រូវបានបង្កើតឡើងដោយការយកវត្ថុមួយមកដាក់ប្រាតិភោគ ឬ ធានា ហើយដែលវត្ថុនោះនឹងក្លាយទៅជាកម្មវត្ថុក្នុងការធានានូវការសងបំណុលដល់ម្ចាស់សិទ្ធិ។ ហើយការបង្កើតប្រាតិភោគនេះដែរ ក៏ត្រូវគោរពនូវគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជនផងដែរ។ ត្រង់ចំណុចលើកឡើងនេះ បានបង្ហាញឲ្យយើងឃើញថា នៅក្នុងកិច្ចសន្យាបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ទំហំនៃអានុភាពទៅលើចលនវត្ថុដែលជាកម្មវត្ថុ គឺអាស្រ័យទៅតាមការកំណត់ និង ព្រមព្រៀងរវាងគូភាគីនៃកិច្ចសន្យាប្រាតិភោគ។ ដូចនេះហើយ វត្ថុនោះក៏ក្លាយទៅជាចំណុចសំខាន់មួយដែលអ្នកសិក្សាគួរធ្វើការវិភាគឲ្យបានច្បាស់លាស់ ថាតើត្រូវកំណត់អានុភាពនៃសិទ្ធិលើវត្ថុនោះដោយរបៀបណា។

### ២. លក្ខណៈនៃវត្ថុដែលជាកម្មវត្ថុ

ពាក្យថាអានុភាពគឺមានវិសាលភាពធំធេងណាស់ ដែលយើងគួរធ្វើការវិភាគ និង បែងចែកឲ្យបានច្បាស់លាស់ដើម្បីជៀសវាងការភ័ន្តច្រឡំ។ តទៅនេះ យើងនឹងធ្វើការសិក្សាទៅលើលក្ខណៈនៃវត្ថុដែលជាកម្មវត្ថុ ព្រោះទំហំនៃសិទ្ធិប្រាតិភោគដោយអនុប្បទានពុំមែនគ្រាន់តែមានទៅលើវត្ថុដែលជាកម្មវត្ថុប៉ុណ្ណោះទេ ពោលគឺត្រូវធ្វើការបែងចែងថាតើសមាសភាគនៃវត្ថុមានអ្វីខ្លះ (២.១) ហើយអ្វីជាវត្ថុភ្ជាប់នឹងវត្ថុជាកម្មវត្ថុ (២.២) ហើយវត្ថុណាជាផ្នែកនៃវត្ថុជាកម្មវត្ថុ (២.៣)។

#### ២.១. សមាសភាគនៃវត្ថុ

សមាសភាគនៃវត្ថុអ្វីមួយ ដែលមិនអាចបែងចែងបានដោយមិនបំបែកវត្ថុនោះ ឬ ដោយមិនផ្លាស់ប្ដូរលក្ខណៈដើមនៃសមាសភាគនោះទេ ភាគនៃវត្ថុនោះមិនអាចក្លាយជាកម្មវត្ថុនៃសិទ្ធិឯករាជ្យបានឡើយ។[30] ក្នុងន័យនេះ ប្រសិនបើមានការធ្វើប្រាតិភោគដោយអនុប្បទានលើចលនវត្ថុណាមួយ ឧទាហរណ៍ កុំព្យូទ័រមួយគ្រឿង នោះការធ្វើប្រាតិភោគនឹងរាប់បញ្ចូលទាំងថ្មកុំព្យូទ័រ អេក្រង់កុំព្យូទ័រ និង ម៉ាស៊ីនដែលធ្វើឲ្យកុំព្យូទ័រដំណើរការ។ មូលហេតុគឺដោយសារថា ថ្ម អេក្រង់ និង ម៉ាស៊ីន គឺជា

[30] ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ១២១ ។

សមាសភាគដែលជាលក្ខណៈដើមរបស់កុំព្យូទ័រ ហើយបើគ្មានគ្រឿងទាំងនេះនឹងបណ្តាលឲ្យផ្លាស់ប្តូរលក្ខណៈដើម ឬ ធ្វើឲ្យកុំព្យូទ័រមិនដំណើរការទៅមុខ។

បើយើងប្រលៃកមើលទៅលើសមាសភាគនៃវត្ថុ យើងត្រូវគិតទៅដល់វត្ថុចំណុះ និង វត្ថុចម្បង។ ក្នុងនេះ ខ្ញុំនឹងលើកឧទាហរណ៍ពី គ្រឿងអាល័ង្ការដែលជាខ្សែរកពេជ្យមួយខ្សែរ ហើយយើងនឹងធ្វើការវិភាគថាតើ វត្ថុណាជាវត្ថុចំណុះ និងមួយណាជាវត្ថុចំបង។ ចំពោះករណីនេះ វាពិបាកបន្តិចក្នុងការកំណត់អំពីវត្ថុចំណុះ និងវត្ថុចម្បង ដោយហេតុថាយើងមិនដឹងថាគួរធ្វើការកំណត់ទៅតាមចំនួនទឹកប្រាក់ ដោយសមាសភាគនៃវត្ថុណាថ្លៃត្រូវចាត់ទុកជាវត្ថុចម្បង ឬយ៉ាងណា។ ជាការពិតទៅ ខ្សែរកក៏អាចក្លាយទៅវត្ថុចំបង ហើយពេជ្រដែលដាំនៅលើខ្សែរកក៏អាចក្លាយជាវត្ថុចម្បងដែរ។ បើក្នុងការអនុវត្តជាក់ស្តែង គេនឹងសម្រេចថាវត្ថុណាជាវត្ថុចំណុះ និងវត្ថុណាជាវត្ថុចម្បងដោយការចរចារ និងព្រមព្រៀងគ្នារបស់គូភាគីតែម្តង។ លើសពីនេះទៅទៀត ភាគីក៏អាចធ្វើប្រាតិភោគដោយអនុប្បទានតែទៅលើវត្ថុចម្បងក៏បាន ដោយព្រមព្រៀងគ្នាថាបង្កើតសិទ្ធិតែទៅលើវត្ថុចម្បង ហើយមិនគិតបញ្ចូលវត្ថុចំណុះនោះឡើយ។

### ២.២. វត្ថុដែលភ្ជាប់នឹងកម្មវត្ថុនៃប្រាតិភោគ

ដូចមានបញ្ញត្តិក្នុងមាត្រា ៨៩១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ សិទ្ធិប្រាតិភោគដោយអនុប្បទាន មានអានុភាពលើវត្ថុដែលភ្ជាប់នឹងវត្ថុដែលជាកម្មវត្ថុ។ ត្រង់ចំណុច យើងអាចសន្មត់បានថា នៅពេលបង្កើតកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន ប្រសិនបើពុំមានចែងឲ្យបានជាក់ច្បាស់ថាធ្វើការបែងចែកនូវវត្ថុដែលជាកម្មវត្ថុនោះទេ អានុភាពនឹងមានទៅលើវត្ថុដែលភ្ជាប់នឹងចលនវត្ថុដែលជាកម្មវត្ថុនោះដោយស្វ័យប្រវត្ត។ ក្នុងនេះផងដែរ ច្បាប់គឺបានផ្តល់សិទ្ធិឲ្យគូភាគីនៃកិច្ចសន្យាធ្វើការជជែកពិភាក្សា ដើម្បីឈានទៅដល់ការព្រមព្រៀងទាំងសងខាង។ ឧទាហរណ៍ ម៉ាញេ ឬ កាមេរ៉ា ដែលភ្ជាប់ទៅនឹងរថយន្ត។ ដូចបានលើកឡើងនៅចំណុចមុន យើងក៏អាចចាត់ទុកថាវត្ថុដែលភ្ជាប់ទៅនឹងកម្មវត្ថុនោះគឺជាវត្ថុចំណុះផងដែរ។ មួយវិញទៀត វត្ថុដែលភ្ជាប់ទៅនឹងវត្ថុដែលជាកម្មវត្ថុ ទោះបីជាត្រូវបានភ្ជាប់នៅក្រោយពេលបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានក៏ដោយ ក៏រាប់បញ្ចូលក្នុងវត្ថុដែលជាកម្មវត្ថុផងដែរប្រសិនជាមិនបានកំណត់នៅក្នុងកិច្ចសន្យាជាមុននោះទេ។ ឧទាហរណ៍ដូចជា កាមេរ៉ា ឬ ម៉ាញេដែលលើកឡើងជាឧទាហរណ៍ខាងលើ ប្រសិនពេលបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានពុំបានចែងជាមុនចំពោះវត្ថុភ្ជាប់នោះទេ ទោះកាមេរ៉ា ឬ ម៉ាញេនោះត្រូវបានភ្ជាប់ក្រោយពេលកិច្ចសន្យាក៏ម្ចាស់សិទ្ធិមានអានុភាពទៅលើវត្ថុទាំងនោះដែរ។

## ២.៣. វត្ថុដែលជាផ្នែកនៃវត្ថុដែលជាកម្មវត្ថុ

ប្រាតិភោគដោយអនុប្បទានក៏បានផ្តល់អានុភាពទៅលើវត្ថុ ដែលជាផ្នែកនៃវត្ថុដែលជាកម្មវត្ថុនៅពេលបង្កើតប្រាតិភោគអនុប្បទានផងដែរ ព្រោះថាបើនិយាយអំពីវត្ថុដែលជាផ្នែកនៃកម្មវត្ថុ យើងគួរគិតទៅដល់សមាសភាគនៃវត្ថុដដែល ដែលបានលើកឡើងនៅចំណុច ២.១ ខាងលើ ពោលគឺសមាភាគនៃវត្ថុអ្វីមួយ មិនអាចបែងចែកបានដោយមិនបំបែកវត្ថុនោះ ឬ ដោយមិនផ្លាស់ប្តូរលក្ខណៈដើមនៃសមាសភាគនោះ។[31] ឧទាហរណ៍ដូចជា កញ្ចក់របស់រថយន្ត ទ្វាររបស់រថយន្ត និង ម៉ាស៊ីនរថយន្តជាដើម។ នេះបានសេចក្តីថា វត្ថុទាំងនេះមិនអាចដកចេញពីរថយន្តបានឡើយ បើពុំនោះទេនឹងបណ្តាលឲ្យផ្លាស់ប្តូររូបរាងដើមរបស់រថយន្ត ឬ ផ្លាស់ប្តូរលក្ខណៈ និង ដំណើរការរបស់រថយន្តជាមិនខាន។ ហេតុដូចនេះហើយ ក្រមរដ្ឋប្បវេណីបានផ្តល់អានុភាពគ្របដណ្តប់ទៅលើវត្ថុដែលជាផ្នែកនៃវត្ថុដែលជាកម្មវត្ថុប្រាតិភោគដោយអនុប្បទាន ដែលយើងអាចសំដៅទៅលើវត្ថុចម្បង។ ក្នុងនោះ ដូចគ្នាទៅនឹងចំណុចមុន ច្បាប់បើកសិទ្ធិឲ្យគូភាគីធ្វើការចរចារទៅលើការបង្កើតសិទ្ធិប្រាតិភោគរបស់ខ្លួន ហើយបើពុំមានចែងអ្វីទេ នោះការបង្កើតប្រាតិភោគដោយអនុប្បទាននឹងមានអានុភាពទៅលើវត្ថុដែលជាផ្នែកនៃវត្ថុដែលជាកម្មវត្ថុ ទោះវត្ថុដែលជាផ្នែកនោះកើតមុន ឬ កើតក្រោយក៏ដោយ។ ជាឧទាហរណ៍ដដែលខាងលើ បើគ្មានចែង សិទ្ធិរបស់ម្ចាស់សិទ្ធិនឹងមានអានុភាពទៅលើកញ្ចក់ ឬ ទ្វារ ឬ ម៉ាស៊ីនរបស់រថយន្តដែលត្រូវបានផ្លាស់ប្តូរជាថ្មី ដែលជាផ្នែកនៃរថយន្តនោះ។

## កថាភាគទី ២៖ អានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទានចំពោះផល

ដោយឡែក សិទ្ធិប្រាតិភោគដោយអនុប្បទានក៏មានអានុភាពផងដែរចំពោះផលដែលកើតចេញពីវត្ថុដែលត្រូវបានយកមកដាក់ប្រាតិភោគដោយអនុប្បទាននោះ។ តួយ៉ាង ចលនវត្ថុដែលយកមកបង្កើតប្រាតិភោគអាចជាវត្ថុដែលជាប្រភពស្វែងរកចំណូលបាន ជាអាទិ៍រួមមាន រថយន្តតាក់ស៊ី សត្វមាន់ដែលមានពងនៅក្នុងកសិដ្ឋានចិញ្ចឹមសត្វ ត្រីក្នុងបឹង ឬ ម៉ាស៊ីនដែលអាចទទួលផលអ្វីមួយពីវាបានជាដើម។ ហើយក្នុងប្រាតិភោគដោយអនុប្បទាន ច្បាប់បានបើកសិទ្ធិចំពោះគូភាគី ពោលគឺវត្ថុដែលជាកម្មវត្ថុនោះអាចស្ថិតក្នុងការកាន់កាប់ដោយម្ចាស់សិទ្ធិផ្ទាល់ ឬ ដោយប្រយោល ហេតុដូចនេះហើយ ក្នុងការបកស្រាយចំណុចនេះឲ្យបានកាន់តែច្បាស់លាស់ ខ្ញុំនឹងធ្វើការអត្ថាធិប្បាយនូវករណីពីរ ពោលគឺករណីអនុប្បទាយីជាអ្នកកាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ (១) និង ករណីអនុប្បទានិកជាអ្នកកាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ (២)។

[31] ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ១២១ ។

## ១. ករណីអនុប្បទាយីកាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ

ក្នុងករណីដែលអ្នកបង្កើត(អនុប្បទាយី) ឬ តតិយជនដែលបានទទួលការបញ្ជាពីអ្នកបង្កើតនោះ កាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ បញ្ញត្តិនៃមាត្រា ៨៩១ (ទំហំដែលមានអានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន) ខាងលើនេះ មិនត្រូវយកមកអនុវត្តចំពោះផលឡើយ។[32] ឃ្លានៅក្នុងមាត្រាដែលលើកឡើងនេះបានសេចក្តីថា ប្រសិនជាវត្ថុដែលជាកម្មវត្ថុស្ថិតនៅក្នុងដៃរបស់អ្នកបង្កើត ឬ តតិយជនដែលទទួលបញ្ជាពីអ្នកបង្កើត នោះផលដែលកើតចេញពីវត្ថុនោះត្រូវបានទៅលើអ្នកបង្កើត ឬ តតិយជនដែលទទួលបញ្ជាពីអ្នកបង្កើត ដោយហេតុថាកូនបំណុលករណីនេះគឺកូនបំណុលបន្តការកាន់កាប់លើវត្ថុ ពោលគឺអាចប្រើប្រាស់ និង អាស្រ័យផលទៅលើវត្ថុដែលជាកម្មវត្ថុបាន។

នៅក្នុងទំហំនៃការប្រើប្រាស់ និង អាស្រ័យផលទៅលើវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាននេះ សិទ្ធិទទួលផលរបស់អនុប្បទាយីត្រូវបានកម្រិតត្រឹមរយៈពេលដែលកិច្ចសន្យាបានដល់ពេលកំណត់ ហើយខ្លួនមិនអនុវត្តកាតព្វកិច្ចទាន់ពេលវេលា ឬ ដល់រយៈមួយដែលអនុប្បទានិក ឬ ម្ចាស់សិទ្ធិធ្វើការទាមទារឲ្យប្រគល់វត្ថុដែលជាកម្មវត្ថុ ដើម្បីធ្វើការចាត់ចែងប្តូរប្រាក់ ឬ អនុប្បទានជាស្ថាពរ។ សូមបញ្ជាក់នៅក្នុងករណីនេះផងដែរថា ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានពុំអាចតតាំងសិទ្ធិនេះ ចំពោះតតិយជនក្រៅពីអ្នកបង្កើតបានឡើយក្នុងករណីដែលមិនបានទទួលការផ្ទេរកាន់កាប់វត្ថុដែលជាកម្មវត្ថុ ដែលចំណុចនេះត្រូវបានបកស្រាយនៅចំណុចខាងលើរួមមកហើយ។

ក្នុងការអនុវត្តជាក់ស្តែង វាជាឧបស័គ្គរបស់ម្ចាស់សិទ្ធិបើខ្លួនពុំមែនជាអ្នកកាន់កាប់វត្ថុដែលជាកម្មវត្ថុនោះចំពោះ ឬ កាន់កាប់ជាក់ស្តែង។ មូលហេតុគឺវាអាចនឹងមានករណីថាដល់ពេលផុតកំណត់កិច្ចសន្យាហើយត្រូវសងបំណុល អ្នកបង្កើតសិទ្ធិធ្វើការគេចខ្លួនមិនប្រគល់វត្ថុដែលជាកម្មវត្ថុនោះទៅឲ្យម្ចាស់សិទ្ធិ ឬ ករណីថាពេលម្ចាស់សិទ្ធិធ្វើការទាមទារប្រគល់វត្ថុដើម្បីចាត់ចែងប្តូរប្រាក់អ្នកបង្កើតបែរជាមិនព្រមប្រគល់វត្ថុ។ ទោះបីជាយ៉ាងណា គូភាគីនៅតែអាចធ្វើការចរចារគ្នាទៅលើការកាន់កាប់វត្ថុនេះនៅពេលបង្កើតកិច្ចសន្យាប្រាតិភោគដោយអនុប្បទានបាន។

## ២. ករណីអនុប្បទានិកកាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ

ករណីដែលម្ចាស់សិទ្ធិកាន់កាប់វត្ថុដែលជាកម្មវត្ថុ នោះវាបានផ្តល់អត្ថប្រយោជន៍ទៅម្ចាស់សិទ្ធិច្រើនជាងករណីមុន។ បើយោងទៅតាមក្រមរដ្ឋប្បវេណីកម្ពុជា កថាខណ្ឌទី២ នៃមាត្រា ៨៩២

[32] ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ៨៩២ ។

ក្នុងករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ឬ តតិយជនដែលបានទទួលការបញ្ជាពីម្ចាស់សិទ្ធិនោះ កាន់កាប់វត្ថុដែលជាកម្មវត្ថុដោយចំពោះ បញ្ញត្តិនៃមាត្រា ៨២២ ត្រូវយកមកអនុវត្ត។ នេះបានសេចក្តីថា ម្ចាស់សិទ្ធិ ឬ តតិយជនដែលទទួលបញ្ជាពីម្ចាស់សិទ្ធិអាចយកផលពីវត្ថុដែលជាកម្មវត្ថុប្រាតិភោគដោយអនុប្បទានបាន ហើយអាចយកផលនោះមកកាត់សិទ្ធិលើបំណុលរបស់ខ្លួន។ ជាពិសេសទៅទៀតនោះ ដោយម្ចាស់សិទ្ធិបានទទួលបានការផ្ទេរការកាន់កាប់ នោះម្ចាស់សិទ្ធិមានអាទិភាពក្នុងការទទួលផលនោះជាងម្ចាស់បំណុលផ្សេងៗទៀតបើមាន។ ការទទួលបានផលនោះត្រូវយកមកកាត់ការប្រាក់នៃសិទ្ធិលើបំណុលជាមុនសិន ហើយប្រសិនបើមានសំណល់ ត្រូវយកទៅកាត់ប្រាក់ដើម[33] បានសេចក្តីថា ក្នុងករណីដែលម្ចាស់សិទ្ធិជាអ្នកកាន់កាប់វត្ថុដែលខ្លួនអាចទទួលផលចេញពីវត្ថុនោះ ម្ចាស់សិទ្ធិពុំអាចទាមទារការប្រាក់ពីកូនបំណុលនោះទេ ដោយត្រូវយកប្រាក់ដែលកើតចេញពីផលនោះមកស៊ីសង រួចពេលសល់យកទៅស៊ីសងបន្តលើប្រាក់ដើមដែលជំពាក់ លើកលែងតែមានការព្រមព្រៀងពិសេស[34]។ ករណីលើកឡើងនេះ អ្នកបង្កើតប្រាតិភោគដោយអនុប្បទានមិនមានសិទ្ធិប្រើប្រាស់ និង អាស្រ័យផលពីវត្ថុដែលជាកម្មវត្ថុ ដែលកថាខណ្ឌទី ២ នៃមាត្រា ៨៩២ នៃក្រមរដ្ឋប្បវេណី ចាត់ចែងដូចគ្នាទៅនឹងសិទ្ធិលើការបញ្ចាំ។

ជាទូទៅ ប្រសិនជាអាចទៅរួច ម្ចាស់បំណុលនឹងខិតខំចរចាររវាងគូភាគីដើម្បីទទួលបានសិទ្ធិកាន់កាប់លើវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទានជាមិនខានឡើយ ព្រោះថាធ្វើដូច្នេះ ម្ចាស់បំណុលនឹងជឿជាក់ប្រាកដថានឹងទទួលបានសំណងរបស់ខ្លួនមកវិញ ព្រោះវត្ថុដែលជាកម្មវត្ថុគឺនៅក្នុងដៃខ្លួនរួចមកហើយ។ ក្នុងករណី អ្នកបង្កើតមិនសងទាន់ពេលកំណត់ ម្ចាស់សិទ្ធិភ្លាមៗនោះអាចធ្វើការចាត់ចែងទៅលើវត្ថុដែលខ្លួនកំពុងកាន់កាប់តែម្តង ដោយសារថាជាធម្មតា វត្ថុដែលជាកម្មវត្ថុនោះត្រូវមានតម្លៃស្មើរ ឬ លើសតម្លៃនៃប្រាក់ដែលឲ្យខ្ចីនោះ។

### កថាភាគទី ៣៖ អានុភាពនៃសិទ្ធិលើបំណុលដែលជាភាគព្វកិច្ច

ដូចដែលយើងបានដឹងមកហើយថា សិទ្ធិប្រាតិភោគដោយអនុប្បទានត្រូវបានបង្កើតឡើងដើម្បីធានាកាតព្វកិច្ចនៃការសងបំណុល ហេតុដូចនេះហើយ អានុភាពនោះក៏កើតមានឡើងទៅលើបំណុលផងដែរ ពោលគឺម្ចាស់សិទ្ធិនឹងមានអានុភាពទៅលើបំណុលដែលជាកាព្វកិច្ចនោះ ដោយទទួលបានការសងបំណុលមុនតតិយជនដែលពុំមានសិទ្ធិ។ ដោយឡែក ក្នុងចំណុចនេះ យើងពុំ

33 ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, មាត្រា ៨២២ ។

34 ក្រសួងយុត្តិធម៌ "សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី២០១០, ភាគ៤ គន្ថីទី៦", ទំព័រ ១០៥ ។

មែនផ្តោតសំខាន់តែទៅលើបំណុលដែលអ្នកបង្កើតធ្វើការខ្ចីប៉ុណ្ណោះទេ ប៉ុន្តែវារមែងមាននូវកត្តាជាច្រើនផ្សេងទៀតដែលត្រូវពិចារណា ក្នុងនោះរួមមាន ប្រាក់ដើម និង តម្លៃការប្រាក់ (១) សំណងប្រាក់នៃទំហំកាតព្វកិច្ច (២) និង វិការៈ និងការមិនអនុវត្តកាតព្វកិច្ច (៣)។

### ១. ប្រាក់ដើម និង តម្លៃការប្រាក់

ជាធម្មតា នៅពេលដែលមានការខ្ចីប្រាក់តាមរូបភាពណាមួយ ម្ចាស់សិទ្ធិនឹងប្រាកដជាមានអានុភាពទៅលើបំណុល ដែលបំណុលនោះនឹងបូករួមទាំងប្រាក់ដើម ព្រមទាំងតម្លៃនៃការប្រាក់ផងដែរ អាស្រ័យទៅតាមការព្រមព្រៀងរបស់គូភាគី។ មិនថាចំពោះប្រាតិភោគដោយអនុប្បទានមួយមុខនេះទេ សូម្បីការខ្ចីប្រាក់តាមមធ្យោបាយផ្សេងៗទៀត ក៏កូនបំណុលត្រូវធ្វើការសងបំណុលឲ្យគ្រប់ចំនួនប្រាក់ដើម និង ផ្តល់នូវតម្លៃការប្រាក់ទៅឲ្យម្ចាស់បំណុលផងដែរប្រសិនមានការព្រមព្រៀងជាមុន។ ជឿជាក់ថាមិត្តអ្នកអានទាំងអស់ប្រាកដជាយល់ច្បាស់អំពីពាក្យថា ប្រាក់ដើមហើយ ដោយប្រាក់ដើមនិយាយឲ្យងាយស្រួល គឺចំនួនទឹកប្រាក់ជាក់ស្តែងដែលកូនបំណុលបានធ្វើការខ្ចីម្ចាស់បំណុលដើម្បីធ្វើអ្វីមួយ។ ដោយឡែក អ្វីទៅជាការប្រាក់? ការប្រាក់ បើយោងទៅតាមសេចក្តីកំណត់ក្រមរដ្ឋប្បវេណីឆ្នាំ២០១០ ការប្រាក់ សំដៅលើទឹកប្រាក់ ឬ វត្ថុផ្សេងទៀត ដែលត្រូវសងជាថ្នូរនឹងការប្រើប្រាស់ប្រាក់ ឬ វត្ថុដើមតាមរយៈពេលនៃការប្រើប្រាស់។ ក្នុងសង្គមខ្មែរយើង ការខ្ចីប្រាក់ដោយផ្តល់បន្ថែមនូវការប្រាក់ គឺជារឿងដែលបុគ្គលគ្រប់រូបអនុវត្ត ពោលគឺធម្មតាទៅហើយ។ ទោះបីជាយ៉ាងណា ច្បាប់បានរឹតត្បិតតម្លៃការប្រាក់ ដោយត្រូវបានកំណត់ដោយប្រកាសរបស់ក្រសួងយុត្តិធម៌ ពោលគឺការប្រាក់មិនត្រូវឲ្យលើសពី ១៨% (ដប់ប្រាំបីភាគរយ) ក្នុងមួយឆ្នាំនោះឡើយ។[35] ហេតុដូចនេះ ទោះបីជាក្នុងករណីប្រាតិភោគដោយអនុប្បទាន ការបង្កើតកិច្ចសន្យាគឺបានបើកសិទ្ធិឲ្យគូភាគីធ្វើការចរចារគ្នាលើប្រការទាំងឡាយក្នុងកិច្ចសន្យា ដើម្បីឈានទៅដល់ការព្រមព្រៀងគ្នាក៏ដោយ ក៏គូភាគីពុំអាចធ្វើការគិតតម្លៃការប្រាក់ហួសប្រមាណភាគរយដែលក្រសួងបានកំណត់នោះដែរ។ លើសពីនេះទៅទៀត ក្នុងករណីដែលថាគូភាគីនៃកិច្ចសន្យាប្រាតិភោគដោយអនុប្បទានពុំបានធ្វើការចែងអំពីល័ក្ខខ័ណ្ឌនៃតម្លៃការប្រាក់នៅពេលដែលបង្កើតកិច្ចសន្យា ក៏ម្ចាស់បំណុលនៅតែមានអានុភាពទៅលើសិទ្ធិក្នុងការទាមទារយកការប្រាក់ បន្ថែមពីលើប្រាក់ដើមផងដែរ។ ចំពោះកាតព្វកិច្ចដែលត្រូវបង្កើតការប្រាក់ ក្នុងករណីដែលគ្មានការកំណត់ផ្សេងទេ ត្រូវគិតអត្រាការប្រាក់ ចំនួន ៥ ភាគរយ (ប្រាំភាគរយ) ក្នុងមួយឆ្នាំ។[36] ក្នុងន័យនេះ គឺគ្រាន់តែផ្តល់ភាព

---

[35] ក្រសួងយុត្តិធម៌, ប្រកាសស្តីពីអត្រាការប្រាក់, លេខ១២៨កយ. ប្រក/,២១ ខែ ធ្នូ ឆ្នាំ ២០១១, ប្រការ ១ ។
[36] ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ៣១៨ ។

ងាយស្រួលដល់គូភាគីកិច្ចសន្យាកាត់បន្ថយនូវករណីដែលអាចកើតមានឡើងនូវវិវាទ ទៅលើការតវ៉ាគ្នារឿងការប្រាក់នេះ ដូចនេះបើគូភាគីមិនអាចឈានទៅដល់ចំណុចរួម គឺមាត្រានេះនឹងត្រូវបានយកមកអនុវត្ត។ ក្រមរដ្ឋប្បវេណីក៏បានបញ្ជាក់អំពីការបង់ការប្រាក់យឺតយ៉ាវផងដែរ ពោលគឺករណីដែលមានការយឺតយ៉ាវមិនបានសងការប្រាក់ សម្រាប់រយៈពេលចាប់ពី ១ (មួយ) ឆ្នាំ ឡើងទៅ ហើយដែលកូនបំណុលចចេះមិនព្រមឲ្យការប្រាក់ ម្ចាស់បំណុលអាចបូកការប្រាក់បញ្ចូលទៅក្នុងប្រាក់ដើមបាន។[37] ក្នុងអានុភាពនៃសិទ្ធិលើបំណុល ម្ចាស់សិទ្ធិត្រូវមានសិទ្ធិអាទិភាពក្នុងការទទួលបានទាំងប្រាក់ដើម និង ការប្រាក់នៅពេលបានបង្កើតកិច្ចសន្យាប្រាតិភោគដោយអនុប្បទានរួចហើយដែលត្រូវទទួលបានមុន ឬ ត្រឹមកាលកំណត់នៃកិច្ចសន្យា។

### ២. សំណងប្រាក់នៃទំហំកាតព្វកិច្ច

ដូចដែលបានលើកឡើងខាងលើនេះពាក់ព័ន្ធទៅនឹងការសងបំណុលទាំងប្រាក់ដើម និង ការប្រាក់ យើងមិនអាចប្រាកដបានថាកូនបំណុលនឹងធ្វើការសងបំណុលដែលខ្ចីនោះទៀតពេលនោះឡើយ ហេតុដូចនេះហើយ ប្រសិនជាមិនទទួលបានសំណងនៅពេលដល់កាលកំណត់នៃកិច្ចសន្យា ម្ចាស់សិទ្ធិអាចធ្វើការទាមទារឲ្យលក់នូវចលវត្ថុដែលជាកម្មវត្ថុនោះ ហើយយកប្រាក់ដែលជាទំហំនៃកាតព្វកិច្ចរបស់កូនបំណុល។ យើងឃើញថា ច្បាប់បានផ្តល់អានុភាពឲ្យម្ចាស់សិទ្ធិត្រឹមតែទំហំនៃកាតព្វកិច្ចក្នុងសំណាង់ប្រាក់នោះតែប៉ុណ្ណោះ។

### ៣. វិការៈ និងការមិនអនុវត្តកាតព្វកិច្ច

ក្នុងការបង្កើតកិច្ចសន្យាមួយ មិនថាកិច្ចសន្យាកិច្ចសន្យាប្រភេទណាឡើយ ប្រសិនជាគូភាគីមិនគោរពនូវកាតព្វកិច្ច នោះកិច្ចសន្យាដែលត្រូវបានបង្កើតឡើងនឹងមានវិការៈ ដែលជាដើមចមឈានទៅដល់ការរំលាយកិច្ចសន្យាបាន។ ដោយឡែក ក្នុងរឿងកិច្ចសន្យាប្រាតិភោគដោយអនុប្បទានក៏ដូចគ្នាផងដែរ។

## ផ្នែកទី២៖ អានុភាពដោយឡែក

ក្រៅពីអានុភាពចំបងដែលបានលើកឡើងខាងលើ ចំណុចនេះនឹងក្តោបលើអត្ថន័យនៃអានុភាពផ្សេងៗ ដែលអ្នកបង្កើតអាចធ្វើការតតាំងនឹងតតិយជនបាន។ ចំណុចខាងក្រោមនេះនឹងធ្វើការបកស្រាយទៅលើ ឧបាទេសកម្មលើវត្ថុ (កថាភាគទី ១) និង បញ្ញត្តិពិសេស (កថាភាគទី ២)។

[37] ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ៣១៩ ។

**កថាភាគទី ១៖ ឧបាទេសកម្មលើវត្ថុ**

ពាក្យថា "ឧបាទេសកម្ម" ក្នុងការចែងនៅសទ្ទានុក្រមផ្នែករដ្ឋប្បវេណីឆ្នាំ ២០០៧ បានឲ្យនិយមន័យពាក្យនេះថាជា ឋានៈមួយដែលបុគ្គលម្នាក់ទទួលជំនួសបុគ្គលណាមួយតាមផ្លូវច្បាប់។ ដូចដែលបានបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណីផងដែរថា *ក្នុងករណីដែលចាំបាច់ដើម្បីរក្សាការពារសិទ្ធិលើបំណុលរបស់ខ្លួន ម្ចាស់បំណុលអាចអនុវត្តសិទ្ធិដែលកូនបំណុលមាន ជំនួសកូនបំណុលបាន។*[38] ការចែងដូចនេះ បានការពារម្ចាស់សិទ្ធិផងដែរក្នុងការរក្សាឲ្យបាននូវវត្ថុដែលជាកម្មវត្ថុ ព្រោះនោះហើយដែលជាការធានាក្នុងបំណុលដែលខ្លួនបានធ្វើកម្ចីទៅអ្នកបង្កើតនោះ។ លើសពីនេះ សិទ្ធិឧបាទេសកម្មនេះ អាចអនុវត្តបានគ្រប់ពេល ល្គិកណាដែលម្ចាស់សិទ្ធិគិតថាចាំបាច់ដើម្បីរក្សាការពារលើវត្ថុនោះ ឬ អាចមានហានិភ័យណាមួយកើតមានឡើង។ ដោយចលនវត្ថុនៅក្នុងបរិបទនៃប្រាតិភោគដោយអនុប្បទានត្រូវបានបែងចែកជា ចលនវត្ថុធម្មតា និង ចលនវត្ថុផ្គុំគ្នា នោះក្នុងចំណុចបន្តទៅទៀតនេះ យើងនឹងសិក្សាលើករណីទាំងនេះ។

**១. ចលនវត្ថុធម្មតា**

ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចអនុវត្តសិទ្ធិរបស់ខ្លួនបាន ចំពោះទឹកប្រាក់ ឬ វត្ថុផ្សេង ដែលអ្នកបង្កើតត្រូវទទួល ដោយការលក់ ការបាត់បង់ ឬ ការខូចខាតនូវវត្ថុដែលជាកម្មវត្ថុ។ ប៉ុន្តែ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ពុំអាចអនុវត្តសិទ្ធិរបស់ខ្លួនបានឡើយ នៅក្រោយពេលដែលប្រាក់ត្រូវបានបង់ ឬ វត្ថុផ្សេងត្រូវបានប្រគល់ទៅឲ្យអ្នកបង្កើត។[39] ដូចបានលើកឡើងក្នុងមាត្រានេះ គឺចង់ផ្តោតសំខាន់ថា ប្រសិនជាអ្នកបង្កើតបានធ្វើការលក់វត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទានទៅឲ្យបុគ្គលណាម្នាក់ផ្សេង ហើយដែលការលក់នោះគឺស្ថិតនៅក្នុងកំឡុងពេលនៃកិច្ចសន្យា នោះម្ចាស់សិទ្ធិមានអានុភាពទៅលើទឹកប្រាក់ដែលបានពីការលក់នោះ ដោយអាចធ្វើការទាមទារយកចំនួនទឹកប្រាក់ ឬ វត្ថុដែលជាទំហំនៃការដាក់ប្រាតិភោគ។ ហើយម្យ៉ាងវិញទៀតនោះម្ចាស់សិទ្ធិក៏អាចធ្វើការអនុវត្តសិទ្ធិទៅលើវត្ថុ ដែលជាកម្មវត្ថុនោះជំនួសអ្នកបង្កើតផងដែរក្នុងករណីចាំបាច់។ ដោយឡែក នៅក្នុងចំណុចទី ១ នៃមាត្រា ៨៩៣ នៃក្រមរដ្ឋប្បវេណីដែលបញ្ញត្តិថា អានុភាពនៃប្រាតិភោគដោយអនុប្បទាន នឹងត្រូវមានចំពោះតម្លៃនៃវត្ថុជំនួសសម្រាប់វត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន។ ក្នុងន័យនេះ បានសេចក្តីថា អ្នកបង្កើតអាចធ្វើការផ្លាស់ប្តូរវត្ថុដែលជា

---

38 ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ៤២២ ។

39 ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ៨៩៣(១) ។

កម្មវត្ថុបានដោយជំនួសវត្ថុណាផ្សេងតាមការចរចាររវាងគូភាគី។

បើអ្នកបង្កើត ដែលបន្តការកាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន នៅក្រោយពេលបង្កើតសិទ្ធិនោះ បានធ្វើអនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនោះទៅឲ្យតតិយជន ឬ បានបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សលើវត្ថុនោះដើម្បីតតិយជន ប្រសិនបើតតិយជននោះបំពេញគ្រប់ល័ក្ខខ័ណ្ឌនៃលទ្ធកម្មដោយសុចរិតនូវកមសិទ្ធិលើចលនវត្ថុ នោះតតិយជននោះអាចយកសិទ្ធិរបស់ខ្លួន ទៅតតាំងចំពោះម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានបាន។ ដោយហេតុដូចនេះហើយ អ្នកបង្កើតអាចធ្វើការយកនូវវត្ថុជំនួសដើម្បីជំនួសនូវវត្ថុដែលជាកម្មវត្ថុបាន។ ដោយសារថាការធ្វើប្រាតិភោគដោយអនុប្បទានបានផ្តល់នូវភាពទូលំទូលាយដល់កូនបំណុល នោះច្បាប់បានបើកសិទ្ធិឱ្យម្ចាស់សិទ្ធិក្នុងការទាមទារឲ្យអ្នកបង្កើត យកវត្ថុអ្វីផ្សេងមកជំនួសក្នុងករណីដែលថាអ្នកបង្កើតបានធ្វើលទ្ធកម្មលើវត្ថុដែលជាកម្មវត្ថុ។

**២. ចលនវត្ថុផ្តុំគ្នា**

ផ្ទុយនឹងករណីខាងលើនេះ ចលនវត្ថុផ្តុំគ្នាគឺមានភាពខុសប្លែក ដោយសារថា វាពិបាកនឹងផ្តល់អានុភាពទៅឲ្យម្ចាស់សិទ្ធិ ពោលគឺម្ចាស់សិទ្ធិមិនអាចអនុវត្តសិទ្ធិឧបាទេសកម្មលើវត្ថុផ្តុំគ្នាឡើយ។ ដូចបានបញ្ញត្តិ បើវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ជាចលនវត្ថុដែលបានកំណត់នៅក្នុងកថាខណ្ឌទី២(ចលនវត្ថុផ្តុំគ្នា) នៃមាត្រា ៨៨៨ នៃក្រមរដ្ឋប្បវេណី ហើយបើអ្នកបង្កើតមានគម្រោងនឹងលក់វត្ថុដែលជាកម្មវត្ថុនេះទៅជនដទៃ សិទ្ធិប្រាតិភោគដោយអនុប្បទានពុំអាចអនុវត្តចំពោះទឹកប្រាក់ដែលបានមកពីការលក់នោះឡើយ។ មូលហេតុដែលច្បាប់ចែងដូច្នេះ គឺដោយសារថា នៅក្នុងការធ្វើប្រាតិភោគដោយអនុប្បទានដែលកម្មវត្ថុគឺចលនវត្ថុផ្តុំគ្នា ជាធម្មវត្ថុ អ្នកបង្កើតប្រាតិភោគនោះឯងជាអ្នកដែលកាន់កាប់វត្ថុដែលជាកម្មវត្ថុដោយផ្ទាល់ ព្រោះខ្លួនត្រូវស្វែងរកចំណូលជាចលនវត្ថុផ្តុំគ្នានោះ។ ឧទាហរណ៍ ទំនិញដែលមានក្នុងហាងលក់ទំនិញមួយជាដើម។ ហេតុដូចនេះហើយ ការលក់ចេញចូលនៃទំនិញនោះ គឺជារឿងធម្មតាដែលម្ចាស់សិទ្ធិមិនមានសិទ្ធិក្នុងការទៅទាមទារទឹកប្រាក់ពីបុគ្គលដែលបានមកទិញទំនិញនេះបានឡើយ។ និយាយជារួមចំពោះចលនវត្ថុផ្តុំគ្នា អ្នកបង្កើតប្រាតិភោគដោយអនុប្បទានមានគម្រោងតាំងពីដំបូង ដើម្បីលក់ចលនវត្ថុទៅអ្នកផ្សេង ហើយគ្មានអានុភាពតាម ហេតុដូច្នេះ គ្មានអានុភាពនៃឧបាទេសកម្មលើវត្ថុផងដែរ។

**កថាភាគទី ២៖ បញ្ញត្តិពិសេស**

ក្នុងការបញ្ញត្តិនីមួយៗ នៅពេលដែលមានគោលការណ៍ណាមួយ វាតែងតែមានភ្ជាប់មកជាមួយនឹងអញ្ញត្រកម្មផងដែរ។ ដូចគ្នាទៅនឹងអានុភាពផងដែរ ប្រាតិភោគដោយអនុប្បទានមិនត្រឹមតែផ្តល់ជូននូវអានុភាពដែលត្រូវបានលើកឡើងបកស្រាយខាងលើនោះទេ ប៉ុន្តែក្នុងនេះមានបញ្ញត្តិនូវអានុភាពពិសេសផងដែរ។ ក្នុងបញ្ញត្តិពិសេសនេះ ករណីដែលម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ឬ តតិយជនដែលទទួលការបញ្ជាពីម្ចាស់សិទ្ធិនោះ កាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុ នោះបញ្ញត្តិនៃមាត្រា ៨២១ (អានុភាពនៃការឃាត់ទុក) មាត្រា ៨២៣ (ករណីយកិច្ចរបស់ម្ចាស់សិទ្ធិលើការបញ្ចាំក្នុងការរក្សាទុកនូវវត្ថុបញ្ចាំ)និង មាត្រា ៨២៤ (សិទ្ធិទាមទារឲ្យសងសោហ៊ុយរបស់ម្ចាស់សិទ្ធិលើការបញ្ចាំ) នៃក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្ត។[40] ក្នុងអត្ថន័យនេះបានសេចក្តីថាប្រាតិភោគដោយអនុប្បទាននឹងត្រូវប្រព្រឹត្តទៅដូចទៅនឹងការបញ្ចាំផងដែរ ព្រោះទំនាក់ទំនងរវាងម្ចាស់សិទ្ធិ និង វត្ថុដែលជាកម្មវត្ថុគឺមានលក្ខណៈស្រដៀងគ្នានឹងទំនាក់ទំនងរវាងម្ចាស់សិទ្ធិលើការបញ្ចាំ និង វត្ថុដែលជាកម្មវត្ថុ។ តាមធម្មតា ក្នុងការបញ្ចាំ និង ប្រាតិភោគដោយអនុប្បទាននេះ គឺមានលក្ខណៈស្រដៀងគ្នាច្រើន គ្រាន់ថាប្រាតិភោគដោយអនុប្បទានមានភាពទូលំទូលាយជាង ដូចជាចលនវត្ថុដែលជាកម្មវត្ថុក្នុងករណីប្រធានបទយើង គឺអាចកើតជារូបភាពចលនវត្ថុធម្មតា និង ចលនវត្ថុផ្តុំគ្នា រីឯក្នុងការបញ្ចាំ គឺគេមិនអាចអនុវត្តទៅលើចលនវត្ថុផ្តុំគ្នាបាននោះទេ។

ក្នុងករណីបញ្ញត្តិពិសេសនេះ តាមរយៈការកាន់កាប់វត្ថុដែលជាកម្មវត្ថុដោយម្ចាស់សិទ្ធិ នាំឲ្យម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានមានសិទ្ធិ និង ករណីយកិច្ចមួយចំនួនទៅលើវត្ថុនោះដូចគ្នាទៅនឹងម្ចាស់សិទ្ធិលើការបញ្ចាំ ដែលសិទ្ធិ និង ករណីកិច្ចនោះរួមមាន អានុភាពឃាត់ទុក និង ទទួលបានសោហ៊ុយ (១) ប៉ុន្តែអានុភាពនេះនឹងត្រូវកម្រិតផងដែរក្នុងករណីមានតតិយជនទទួលបាននូវលទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ (២) និង ករណីតតិយជនបានទទួលបញ្ជាជាអ្នកកាន់កាប់វត្ថុដែលជាកម្មវត្ថុ (៣)។

### ១. អានុភាពឃាត់ទុក និង ទទួលបានសោហ៊ុយ

ដោយហេតុថាបញ្ញត្តិពិសេសនេះ គឺផ្តោតសំខាន់លើករណីដែលម្ចាស់សិទ្ធិគឺជាអ្នកកាន់កាប់វត្ថុ ហេតុដូចនេះហើយបើយើងមើលឲ្យលម្អិតទៅ ការធ្វើប្រាតិភោគនេះគឺមានភាពស្រដៀងគ្នាទៅនឹងការបញ្ចាំផងដែរ ដែលការកាន់កាប់វត្ថុដែលជាកម្មវត្ថុនោះស្ថិតក្នុងដៃរបស់ម្ចាស់បំណុល។ ដូចនេះហើយ អានុភាពដែលមានទៅលើវត្ថុនោះក៏មានលក្ខណៈដូចគ្នាទៅនឹងករណីនៃការបញ្ចាំ

[40] ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ៨៩៦ ។

ចលនវត្ថុផងដែរ។ ម្ចាស់សិទ្ធិលើការបញ្ចាំអាចឃាត់ទុកវត្ថុបញ្ចាំបាន រហូតដល់ពេលដែលទទួលការសងចំពោះសិទ្ធិលើបំណុលដែលជាទំហំនៃកាតព្វកិច្ច។ ប៉ុន្តែ សិទ្ធិនេះមិនអាចតតាំង ចំពោះម្ចាស់បំណុលដែលមានអាទិភាពជាងខ្លួនបានឡើយ។[41] ការចែងបែបនេះបានផ្តល់ឱកាសឲ្យម្ចាស់សិទ្ធិក្នុងការជួយរំលឹកកូនបំណុលដោយប្រយោល តាមរយៈអានុភាពឃាត់ទុកនៃសិទ្ធិដើម្បីទទួលការសងចំពោះសិទ្ធិបំណុល។ ធ្វើដូច្នេះអាចឲ្យម្ចាស់សិទ្ធិអាចទទួលសំណងឆាប់រហ័ស និងទាន់ពេលវាលា។ លើសពីនេះទៅទៀត ម្ចាស់សិទ្ធិក៏មានអានុភាពផងដែរក្នុងការទទួលបាននូវសោហ៊ុយដែលចំណាយទៅវត្ថុដែលជាកម្មវត្ថុនោះ។ ដោយម្ចាស់សិទ្ធិលើប្រាតិភោគដោយអនុប្បទាន ដូចទៅនឹងការបញ្ចាំ ត្រូវកាន់កាប់វត្ថុបញ្ចាំនោះដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិតនោះហើយម្ចាស់សិទ្ធិលើការបញ្ចាំបានចេញចំណាយជាចាំបាច់សម្រាប់ការគ្រប់គ្រង និង ថែរក្សាវត្ថុចំពោះវត្ថុបញ្ចាំ ដែលក្នុងករណីបែបនេះ ម្ចាស់សិទ្ធិអាចទាមទារឲ្យកម្មសិទ្ធិករនៃវត្ថុនោះសងនូវចំណាយនោះវិញបាន។[42] ឧទាហរណ៍ ម្ចាស់សិទ្ធិជាអ្នកកាន់កាប់ទៅលើរថយន្តមួយ ដែលគាត់ត្រូវមានកាតព្វកិច្ចថែរក្សារថយន្ត ដូចជាលាងសម្អាតរថយន្ត ឬ ការប្តូរអាគុយជាដើម ដូចឧទាហរណ៍ដែលបានលើកឡើងនេះ ម្ចាស់សិទ្ធិអាចធ្វើការទាមទារទៅលើសោហ៊ុយដែលខ្លួនបានចំណាយនោះបាន។ អ្វីដែលពិសេសជាងនេះទៅទៀតនោះ គឺម្ចាស់សិទ្ធិថែមទាំងអាចធ្វើការទាមទារនូវតម្លៃប្រាក់ដែលវត្ថុនោះកើនឡើងក្នុងកំឡុងពេលកាន់កាប់របស់ខ្លួន ដោយធ្វើការទាមទារទៅតុលាការហើយតុលាការអាចកំណត់ពេលសមរម្យដើម្បីសងទៅតាមការទាមទាររបស់កម្មសិទ្ធិករបាន។

## ២. ការទទួលបាននូវផលទុកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ

សព្វថ្ងៃនេះ នៅក្នុងការបង្កើតប្រាតិភោគដោយអនុប្បទាន គេរមែងតែងជួបប្រទះនូវការអនុវត្តដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងកិច្ចសន្យានៃការបញ្ចាំចលនវត្ថុ ដែលកាលកំណត់ភាគច្រើនគឺមានរយៈពេលចំនួន ៣០ ថ្ងៃ ដែលនៅក្នុងកាលកំណត់នេះត្រូវធ្វើការសងនូវកម្ចីឲ្យបានរួចរាល់។ ដោយឡែក ក្នុងរឿងប្រាតិភោគដោយអនុប្បទាន ច្បាប់បានបញ្ញត្តិយ៉ាងទូលំទូលាយផ្តល់សិទ្ធិទៅលើគូភាគីក្នុងការចរចារក្នុងការឲ្យភាគីណាម្នាក់កាន់កាប់វត្ថុដែលជាកម្មវត្ថុនោះ ហើយនៅក្នុងការបង្កើតកិច្ចសន្យា ដោយសារគូភាគីណាម្ខាងអាចមានសិទ្ធិទៅលើវត្ថុដែលត្រូវបានដាក់ប្រាតិភោគនោះ ហេតុនេះហើយ ម្ចាស់សិទ្ធិ ឬ អ្នកបង្កើតដែលជាអ្នកកាន់កាប់នោះអាចធ្វើការចាត់ចែងលើវត្ថុនោះបាន។

41 ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ៨២១(១) ។
42 ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ៨២៤ ។

ក្នុងករណីដែលម្ចាស់សិទ្ធិជាអ្នកកាន់កាប់ទៅលើវត្ថុដែលជាកម្មវត្ថុ ការចាត់ចែងវត្ថុរបស់ម្ចាស់សិទ្ធិអាចធ្វើឲ្យជះឥទ្ធិពលទៅលើកូនបំណុល។ ដូចបានលើកឡើងនេះ ប្រសិនជាម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានដែលកាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុ បានធ្វើអនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនោះទៅតតិយជន ឬ បានបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សលើវត្ថុនោះដើម្បីតតិយជន ប្រសិនបើតតិយជននោះ បំពេញគ្រប់ល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងមាត្រា ១៩៣ (លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ) នៃក្រមនេះ តតិយជននោះអាចយកសិទ្ធិរបស់ខ្លួនទៅតតាំងចំពោះអ្នកបង្កើតបាន។[43] នេះបានសេចក្តីថា ក្នុងករណីដែលម្ចាស់សិទ្ធិកាន់កាប់វត្ថុដោយផ្ទាល់ បន្ទាប់ពីការបង្កើតកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន គឺម្ចាស់សិទ្ធិអាចធ្វើការចាត់ចែងវត្ថុនោះទៅតតិយជន។ ម្យ៉ាងវិញទៀត នៅក្នុងពេលដែលវត្ថុនោះត្រូវបានចាត់ចែងទៅឲ្យតតិយជនរួចគឺអ្នកបង្កើតមិនអាចធ្វើការទាមទារ ឬ តតាំងចំពោះតតិយជនបានឡើយ ពោលគឺអាចតតាំងបានតែចំពោះភាគីនៃកិច្ចសន្យាតែប៉ុណ្ណោះ ហើយ អ្នកបង្កើតសិទ្ធិប្រាតិភោគនោះក៏មិនអាចអនុវត្តសិទ្ធិទទួលយកមកវិញចំពោះតតិយជនបានដែរ។

ក្នុងករណីមួយទៀត ដែលការកាន់កាប់វត្ថុដែលជាកម្មវត្ថុស្ថិតក្នុងដៃអ្នកបង្កើតវិញ បើអ្នកបង្កើតជាអ្នកបន្តការកាន់កាប់ដោយចំពោះ នូវវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទាននៅក្រោយពេលបង្កើតសិទ្ធិនោះ បានធ្វើអនុប្បទាននូវវត្ថុដែលជាកម្មវត្ថុនោះទៅតតិយជន ឬ បានបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សលើវត្ថុនោះដើម្បីតតិយជន ប្រសិនបើតតិយជននោះបំពេញគ្រប់ល័ក្ខខ័ណ្ឌនៃលទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ តតិយជននោះអាចយកសិទ្ធិរបស់ខ្លួនទៅតតាំងចំពោះម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានបាន។[44] ចំណុចនេះដូចទៅនឹងករណីមុនដែរ គឺម្ចាស់សិទ្ធិមិនអាចទៅតតាំងនឹងតតិយជនបានឡើយ ករណីដែលវត្ថុនោះត្រូវបានធ្វើលទ្ធកម្មទៅឲ្យជនដទៃទៀត។

43 ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ៨៩៧(១) ។

44 ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ៨៩៨(១) ។

# ជំពូកទី ៣
# ដំណើរប្រព្រឹត្តទៅនៃប្រាតិភោគដោយអនុប្បទាន

បន្ទាប់ពីបានយល់ច្បាស់អំពីរបបគតិយុត្តនៃប្រាតិភោគដោយអនុប្បទាន និង អានុភាពនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ដែលក្នុងនោះរួមមាន សញ្ញាណទូទៅ ល័ក្ខខ័ណ្ឌសុពលភាពនៃសិទ្ធិ ព្រមទាំងអានុភាពចំបង អានុភាពដោយឡែកជាដើម ជឿជាក់ថាប្រាកដជាបានញ៉ាំងឲ្យមិត្តអ្នកអានទាំងឡាយទទួលបាននូវចំណេះដឹង និង គោលគំនិតជាច្រើនពាក់ព័ន្ធនឹងរឿងប្រាតិភោគដោយអនុប្បទានជាមិនខាន។ ហេតុដូចនេះហើយ នៅក្នុងជំពូកនេះ ខ្ញុំនឹងធ្វើការបង្ហាញអំពីដំណើរប្រព្រឹត្តទៅនៃប្រាតិភោគដោយអនុប្បទាន ដែលជាជំពូកមួយអាចជួយបង្កើននូវការយល់ដឹងទៅមិត្តអ្នកអានទាំងឡាយ ឆ្លើយតបទៅនឹងការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាននៅក្នុងព្រះរាជាណាចក្រកម្ពុជា (ផ្នែកទី១) ភ្ជាប់ជាមួយនឹងការផ្តល់ជាយោបល់ទៅលើ ហានិភ័យ និង អាជ្ញាយុកាល (ផ្នែកទី២)។

## ផ្នែកទី១៖ ការអនុវត្តសិទ្ធិប្រាតិភោគដោយអនុប្បទាននៅក្នុងព្រះរាជាណាចក្រកម្ពុជា

ក្នុងសង្គមកម្ពុជាប្រចាំថ្ងៃនេះ ដោយហេតុថាប្រាតិភោគប្រត្យក្សប្រភេទថ្មីមួយនេះទើបមានកំណើតក្នុងពេលបច្ចុប្បន្ននេះ ដូចនេះគេពុំសូវប្រទះឃើញមានការអនុវត្តជាក់ស្តែងទៅលើករណីប្រាតិភោគដោយអនុប្បទាននេះឡើយ។ ដោយឡែក ប្រជាជនភាគច្រើននៅតែបន្តអនុវត្តនូវបញ្ញត្តិនៃការបញ្ចាំដដែលព្រោះថា ការបញ្ចាំត្រូវបានអ្នករាល់គ្នាអនុវត្តតាំងពីដើមមក។ ជាក់ស្តែង យើងក៏ឃើញមានហាងមួយចំនួនដែលបើកទទួលបញ្ចាំចលនវត្ថុ ហើយនៅក្នុងយីហោ បែរជាបន្ថែមពីក្រោយ "ការបញ្ចាំចលនវត្ថុ" ដាក់ពាក្យថា "ប្រាតិភោគដោយអនុប្បទាន" ទៅវិញ។ ដូចបានលើកឡើងនេះ យើងអាចយល់បានថា បុគ្គលភាគច្រើននៅក្នុងសង្គមខ្មែរពុំទាន់សូវយល់ដឹងអំពីប្រាតិភោគដោយអនុប្បទាន និង ការអនុវត្តរបស់ប្រាតិភោគដោយអនុប្បទានបានច្បាស់លាស់ និង ជាក់លាក់នៅឡើយទេ ដោយភាគច្រើនគេគិតថាការអនុវត្តការបញ្ចាំ និង ការអនុវត្តប្រាតិភោគដោយអនុប្បទានគឺមានលក្ខណៈដូចគ្នាតែម្តង។ ម្យ៉ាងវិញទៀត ការបញ្ញត្តិក៏ភាគច្រើនកើតមានតែមួយផងដែរ ឧទាហរណ៍ដូចជា ប្រកាសដែលចេញពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពោលគឺប្រកាសស្តីពីការគ្រប់គ្រង់អាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន[45]។ ផ្ទុយទៅវិញ ការអនុវត្តប្រាតិភោគដោយអនុប្បទានគឺមានភាពខុសគ្នា ដោយយើងគួរសិក្សាទៅលើដំណើរ

---

45 ប្រកាសលេខ ០៣០ សហវ.ប្រក របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពី ការគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន។

ការប្រព្រឹត្តទៅរបស់វា។ ជាបន្តទៅទៀតនេះ ខ្ញុំនឹងធ្វើការបកស្រាយលម្អិតទៅលើចំណុចទាំងនេះ។

### កថាភាគទី ១៖ កិច្ចដំណើរការនៃការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន

នៅក្នុងកិច្ចដំណើរការនៃប្រាតិភោគដោយអនុប្បទាន ការអនុវត្តគឺមានលក្ខណៈដូចទៅនឹងកិច្ចដំណើរការនៃការបង្កើតសិទ្ធិ ឬ កិច្ចសន្យាផ្សេងៗផងដែរ កិច្ចដំណើរការនេះគឺត្រូវឆ្លងកាត់ដំណាក់កាលនៃការបង្កើតកិច្ចសន្យា ដោយយើងត្រូវបំពេញនូវល័ក្ខខ័ណ្ឌដូចបានលើកឡើងនៅក្នុងជំពូកទី ១ ពោលគឺ ល័ក្ខខ័ណ្ឌគ្រឹះ និង ល័ក្ខខ័ណ្ឌទម្រង់ បូករួមទាំងល័ក្ខខ័ណ្ឌតតាំងផងដែរ។ កិច្ចសន្យាប្រាតិភោគដោយអនុប្បទាន គឺជាប្រភេទនៃកិច្ចសន្យាដែលភាគីនីមួយៗមានកាតព្វកិច្ចទៅវិញទៅមក ដូចជា កិច្ចសន្យាម៉ៅការ ឬ កិច្ចសន្យាខ្ចីបរិភោគជាដើម។ កិច្ចដំណើរការនៃការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានពុំមានភាពស្មុគស្មាញដូចការបង្កើតសិទ្ធិផ្សេងៗឡើយ ដោយហេតុថាការបង្កើតកិច្ចសន្យាគឺអាចធ្វើតែត្រឹមជាលិខិតឯកជនតែប៉ុណ្ណោះ ហើយនីតិវិធីនៅពេលមានវិវាទក៏អាចពុំចាំបាច់មានឆ្លងកាត់ប្រព័ន្ធតុលាការផងដែរ ពោលគឺប្រព្រឹត្តទៅនៅក្រៅប្រព័ន្ធតុលាការ ហើយនីតិវិធីគឺមានភាពងាយស្រួលសម្រាប់គូភាគីធ្វើការព្រមព្រៀងគ្នា។ ក្នុងកិច្ចដំណើរការនៃការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន រយៈពេលផុតកំណត់នៃកិច្ចសន្យាគឺអាស្រ័យទៅតាមការកំណត់ និង ចរចាររបស់គូភាគី ដែលទូទៅវាផ្អែកទៅលើទំហំនៃប្រាក់កម្ចី។ ភាគីច្រើនបើមើលលើការអនុវត្ត កិច្ចសន្យាតែងចែងឲ្យមានរយៈពេល ៣០ ថ្ងៃ ឬ អាចលើសពីរយៈពេលនេះទៅតាមលទ្ធភាពដែលកូនបំណុលអាចធ្វើការសងបាន។ នៅក្នុងកិច្ចសន្យាខ្លះទៀតដែលទំហំនៃទឹកប្រាក់មានភាពធំធេង ការសងប្រាក់កម្ចីនឹងត្រូវបានបែងចែកជាដំណាក់កាលតូចៗដែលមានកំណត់រយៈពេលវែង។ ការបកស្រាយក្នុងចំណុចបន្ទាប់នេះនឹងផ្តោតសំខាន់ទៅលើករណីពីរ ពោលគឺករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចទាន់ពេលវេលា និង ករណីដែលកូនបំណុលបានផ្តល់តាវកាលិកទៅឲ្យម្ចាស់សិទ្ធិវិញចប់សព្វគ្រប់។

### កថាភាគទី ២៖ ការចាត់ចែងវត្ថុ

ជាធម្មតា នៅពេលដែលមានការធ្វើប្រាតិភោគដោយអនុប្បទាន គឺតែងមានការផ្ទេរនូវការកាន់កាប់នូវវត្ថុដែលជាកម្មវត្ថុ។ ហេតុដូចបានលើកឡើងនេះ នៅពេលដែលកិច្ចសន្យាត្រូវបានផុតកំណត់ ការកាន់កាប់ទៅលើវត្ថុនោះក៏បានផុតកំណត់ដែរ ដែលអ្នកកាន់កាប់វត្ថុដោយចំពោះត្រូវធ្វើការប្រគល់វត្ថុទៅឲ្យអ្នកបង្កើតវិញ ឬ ធ្វើការចាត់ចែងទៅលើវត្ថុនោះក្នុងករណីដែលមិនបានទទួលនូវសំណងរបស់ខ្លួន។ យើងដឹងហើយថា ក្នុងការធ្វើប្រាក់កម្ចី គេមិនដែលប្រាកដជាក់

ច្បាស់ថាកូនបំណុលប្រាកដជានឹងផ្តល់សំណងមកវិញទាន់ពេលឡើយ ហេតុដូចនេះហើយ ក្រមរដ្ឋប្បវេណីបានបញ្ញត្តិអំពីការចាត់ចែងវត្ថុ ដែលនេះជាចំណុចដែលអាចការពារផលប្រយោជន៍របស់ម្ចាស់សិទ្ធិខ្លួនឯងផ្ទាល់បាន។

### ១. ការប្តូរវត្ថុដែលជាកម្មវត្ថុជាប្រាក់

នៅក្នុងករណីដែលថាម្ចាស់សិទ្ធិមិនបានទទួលសំណងទាន់ពេលវេលានោះទេ ម្ចាស់សិទ្ធិអាចធ្វើការទាមទារឲ្យមានការប្តូរវត្ថុដែលជាកម្មវត្ថុជាប្រាក់បាន។ ដូចមានចែងនៅក្រមរដ្ឋប្បវេណី បើកាតព្វកិច្ចពុំត្រូវបានអនុវត្ត ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន អាចប្តូរវត្ថុដែលជាកម្មវត្ថុនោះជាប្រាក់ ដោយផ្ទាល់ខ្លួន ឬ ធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុជាស្ថាពរបាន ដោយជូនដំណឹងទៅអ្នកបង្កើត។ តាមការចែងក្នុងកថាខណ្ឌទី ១ នេះ ច្បាប់បានផ្តល់អំណាចទៅឲ្យម្ចាស់បំណុលក្នុងការធ្វើការប្តូរវត្ថុទៅជាប្រាក់ ឬ អាចធ្វើលទ្ធកម្មទៅឲ្យតតិយជនដែលការធ្វើលទ្ធកម្មនោះត្រូវប្រព្រឹត្តដោយបំពេញនូវល័ក្ខខ័ណ្ឌដែលមានចែងនៅក្នុងមាត្រា ១៩៣ ស្តីអំពីលទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ។ ក្រោយពីបានធ្វើការប្តូរវត្ថុនោះជាប្រាក់ ឬ ធ្វើលទ្ធកម្មទៅលើវត្ថុរួចអ្នកបង្កើតគឺពុំអាចធ្វើការតតាំងបានឡើយ។

បើក្នុងករណីដែលវត្ថុដែលជាកម្មវត្ថុត្រូវបានកាន់កាប់ដោយតតិយជនដែលបានទទួលបញ្ញានោះម្ចាស់សិទ្ធិអាចធ្វើការទាមទារយកវត្ថុនោះមកវិញដើម្បីធ្វើការលក់ ឬ ធ្វើលទ្ធកម្ម។ ម្យ៉ាងទៀតបើតម្លៃនៃវត្ថុដែលជាកម្មវត្ថុមានចំនួនលើសពីចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលត្រូវសង ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានត្រូវបង់ចំនួនទឹកប្រាក់ដែលលើសនោះ ទៅឲ្យអ្នកបង្កើត ដោយចាត់ជាប្រាក់ជម្រះ។ តាមសេចក្តីពន្យល់ ម្ចាស់សិទ្ធិករណីកិច្ចសងប្រាក់ជម្រះ ដើម្បីកុំឲ្យម្ចាស់សិទ្ធិនោះទទួលចំនេញហួសហេតុពេក។ តែទោះជាយ៉ាងណា ក្នុងការអនុវត្តជាក់ស្តែងវិញ គេសង្កេតឃើញថា នៅតាមហាងបញ្ចាំ ឬ ប្រាតិភោគដោយអនុប្បទាន ម្ចាស់សិទ្ធិភាគច្រើនមិនធ្វើការប្រគល់ ឬចាត់ចែងប្រាក់លើសទៅឲ្យអ្នកបង្កើតវិញឡើយ។ នោះហើយ ប្រសិនជាដល់ពេលកំណត់កិច្ចសន្យាម្ចាស់សិទ្ធិនឹងអនុវត្តសិទ្ធិទៅលើវត្ថុដែលជាកម្មវត្ថុនោះតែម្តង។

ក្នុងការចែងបែបនេះ ពុំមែនបានសេចក្តីថាក្រោយការចាត់ចែងវត្ថុជាប្រាក់នោះ អ្នកបង្កើតពុំអាចធ្វើអ្វីបាននោះទេ ពោលគឺប្រសិនជាអ្នកបង្កើតគិតថាមិនត្រឹមត្រូវ ឬ សុខចិត្តលើការប្តូរវត្ថុជាប្រាក់ ឬ ការធ្វើលទ្ធកម្មរបស់ម្ចាស់សិទ្ធិនោះទេ អ្នកបង្កើតអាចធ្វើការតវ៉ាទៅតុលាការមានសមត្ថកិច្ចបាន ដោយលើកឡើងនូវហេតុផលឲ្យបានច្បាស់លាស់ និងសមស្រប។

### ២. អនុប្បទានជាស្ថាពរ

ការបកស្រាយខាងលើ គឺគ្រាន់តែជាមួយផ្នែកនៃការចាត់ចែងវត្ថុដែលជាកម្មវត្ថុតែប៉ុណ្ណោះ ក្រៅពីការយកវត្ថុនោះទៅប្តូរជាប្រាក់ ម្ចាស់សិទ្ធិក៏អាចធ្វើលទ្ធកម្មនូវវត្ថុដែលជាកម្មវត្ថុកិច្ចសន្យាផងដែរ។ ដោយករណីខ្លះ ម្ចាស់សិទ្ធិមានបំណងចង់ទទួលទុកនូវវត្ថុនោះតែម្តង ដូចនេះម្ចាស់សិទ្ធិអាចធ្វើអនុប្បទានជាស្ថាពរ ដោយធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុដែលបានដាក់ធានានោះតែម្តង។ ដូចទៅនឹងករណីមុនផងដែរ ប្រសិនជាវត្ថុនោះមានតម្លៃថ្លៃលើសលុប គូភាគីអាចធ្វើការចរចារដើម្បីឲ្យម្ចាស់សិទ្ធិធ្វើការទូទាត់ទឹកប្រាក់ដែលលើស ដោយចាត់ជាប្រាក់ជម្រះទៅឲ្យអ្នកបង្កើតវិញ។ បើយើងមើលទៅលើករណីអនុប្បទានជាស្ថាពរនេះ វាហាក់បីដូចជាមានលក្ខណៈជាការទិញលក់យ៉ាងដូច្នេះដែរ ព្រោះថាម្ចាស់បំណុលបានប្រគល់ប្រាក់ទៅឲ្យកូនបំណុល ហើយកូនបំណុលបានប្រគល់វត្ថុមកឲ្យម្ចាស់បំណុលវិញដែរ។ ប៉ុន្តែ ទោះបីជាមានភាពស្រដៀងគ្នាយ៉ាងណាក៏ដោយ ការធ្វើអនុប្បទានជាស្ថាពរនេះធ្វើនៅក្នុងបដិបទនៃប្រាតិភោគដោយអនុប្បទាន ដែលនីតិវិធីគឺមិនមានភាពដូចគ្នាឡើយទៅនឹងការទិញលក់។

នៅក្នុងការអនុវត្តជាក់ស្តែង នៅពេលមានករណីអនុប្បទានជាស្ថាពរបែបនេះកើតមានឡើង គេសង្កេតឃើញថា ម្ចាស់សិទ្ធិពុំបានធ្វើការចាត់ចែងប្រាក់ជម្រះមកឲ្យអ្នកបង្កើតនោះឡើយ គឺខ្លួនទទួលយកវត្ថុនោះទាំងស្រុងតែម្តង តាមការធ្វើលទ្ធកម្មកម្មសិទ្ធិទៅលើវត្ថុនោះ។

សរុបសេចក្តីមក មធ្យោបាយទាំងពីរខាងលើ ក្នុងករណីកូនបំណុលមិនធ្វើការសងកម្ចីទាន់ពេលវេលានេះ គឺយើងអាចអនុវត្តសិទ្ធិរបស់ខ្លួនបានដូចមានបកស្រាយនេះ។ ទោះបីមានចែងដូចនេះក្តី ក៏វាហាក់ដូចជាអត្ថន័យនៅមានភាពទូលំទូលាយផងដែរ ព្រោះការអនុវត្តជាក់ស្តែងកន្លងមកគឺមិនបានអនុលោមតាមច្បាប់ទាំងស្រុងទេ តែវាអាស្រ័យទៅតាមការចរចារនៃគូភាគីកិច្ចសន្យាតែប៉ុណ្ណោះ។ ហើយម្យ៉ាងវិញទៀត មិនសូវមានឡើយការដេញដោលគ្នា និងទាមទារយកប្រាក់នោះដោយធ្វើការប្តឹងទៅតុលាការ ព្រោះជាទូទៅ គឺច្រើនតែមានការអត់អោននៅពេលមានភាពលើសលុបកើតមានឡើង។

### កថាភាគទី ៣៖ ការប្រគល់វត្ថុដែលជាកម្មវត្ថុឲ្យអ្នកបង្កើត

វត្ថុដែលជាកម្មវត្ថុក្នុងប្រាតិភោគដោយអនុប្បទាន គឺធ្វើការដាក់ធានាដើម្បីខ្ចីប្រាក់ នេះបានឲ្យយើងដឹងថា កាលណាដែលកាតព្វកិច្ចត្រូវបានបំពេញ វត្ថុដែលជាកម្មវត្ថុក៏លែងត្រូវជាកម្មវត្ថុនៃកិច្ចសន្យាទៀតដែរដោយហេតុថាកិច្ចសន្យានោះនឹងរលត់។ ដូចមានចែង ទោះបីជាពេលកំណត់

ត្រូវសងកាតព្វកិច្ចបានកន្លងផុតក៏ដោយ ក៏អ្នកបង្កើតអាចទទួលយកមកវិញនូវវត្ថុដែលជាកម្មវត្ថុ ដោយផ្តល់នូវកាតព្វកិច្ចគ្រប់ចំនួន និង បង្ហាញអំពីការផ្តល់នោះទៅម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានបាន នៅមុនពេលមានការផ្តល់ប្រាក់ជម្រះ។ ការចែងបែបនេះ មានបំណងបញ្ជាក់ឲ្យច្បាស់អំពីអំឡុងពេលដែលកូនបំណុលមានសិទ្ធិទទួលយកមកវិញ នូវវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន ដោយការសងកាតព្វកិច្ចរបស់ខ្លួន ដែលនេះហើយគេហៅថា សិទ្ធិទទួលយកមកវិញ។ បើយើងធ្វើការវិភាគទៅ មាត្រានេះមានគោលបំណងការពារអ្នកបង្កើតប្រាតិភោគដោយអនុប្បទានឲ្យបានច្រើនតាមដែលអាចធ្វើបាន ក្នុងទំហំដែលមិនធ្វើឲ្យខូចខាតដល់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន ប៉ុន្តែករណីដែលមិនមានប្រាក់ជម្រះទេ អ្នកបង្កើតប្រាតិភោគដោយអនុប្បទានមិនអាចអនុវត្តសិទ្ធិទទួលយកមកវិញបានឡើយ បើទោះជាក្រោយពេលម្ចាស់សិទ្ធិបានជូនដំណឹងអំពីហេតុដែលមិនមានប្រាក់ជម្រះ។

## ផ្នែកទី២៖ ហានិភ័យ និង អាជ្ញាយុកាល

ក្រោយពីបានយល់ច្បាស់អំពីការអនុវត្តប្រាតិភោគដោយអនុប្បទាន ព្រមទាំងការចាត់ចែងវត្ថុដែលជាកម្មវត្ថុ ដោយធ្វើការប្តូរជាប្រាក់ ឬ លទ្ធកម្ម និង ការធ្វើអនុប្បទានស្ថាពរ យើងរមែងត្រូវយល់ឲ្យបានច្បាស់ផងដែរអំពីហានិភ័យ និង អាជ្ញាយុកាលរបស់វា។ ជាក់ស្តែងយើងដឹងហើយថាប្រតិបត្តិការណាក៏ដោយក៏តែងមានភាគរយនៃហានិភ័យដើតមានឡើងដែរ រីឯកិច្ចសន្យាវិញក៏វាប្រាកដជាមានអាជ្ញាយុកាលរបស់វា ហេតុដូចនេះហើយ មុននឹងធ្វើប្រតិបត្តិការប្រាតិភោគដោយអនុប្បទាន យើងគួរយល់ដឹងផងដែរទៅលើហានិភ័យដែលអាចកើតមានឡើង (កថាភាគទី១) ព្រមទាំងអាជ្ញាយុកាលនៃកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន (កថាភាគទី២)។

### កថាភាគទី ១៖ ហានិភ័យដែលអាចកើតមានឡើង

ហានិភ័យគឺជាចំណុចសំខាន់ដើម្បីឲ្យបណ្តាបុគ្គលទាំងឡាយណា ដែលមានបំណងចង់យល់ដឹងអំពីការបង្កើត និងការអនុវត្តប្រាតិភោគដោយអនុប្បទាន ព្រោះថាដោយដឹងអំពីហានិភ័យដែលអាចកើតមានឡើង យើងនឹងអាចត្រៀមខ្លួន និង មានភាពប្រុងប្រយ័ត្នចំពោះសកម្មភាពទាំងឡាយដែលយើងប្រព្រឹត្ត។ ដោយឡែក នៅក្នុងប្រាតិភោគដោយអនុប្បទានក៏មានហានិភ័យច្រើនកើតមានឡើងដែរ ហើយបើធ្វើការវិភាគ និង បែងចែកឲ្យងាយយល់ ហានិភ័យនោះអាចកើតទៅលើម្ចាស់បំណុល (១) និងមានករណីពាក់ព័ន្ធនឹងកូនបំណុល (២) ផងដែរ។

**១. ករណីពាក់ព័ន្ធនឹងម្ចាស់បំណុល**

ហានិភ័យអាចកើតមានឡើងគ្រប់ពេលវេលា ហើយដែលក្នុងករណីនេះ ខ្ញុំនឹងលើកយកចំណុចហានិភ័យដែលអាចកើតមានឡើងចំពោះម្ចាស់បំណុលមកបង្ហាញខ្លះៗ។ ក្នុងនេះផងដែរ ដោយសារថាក្នុងករណីប្រាតិភោគដោយអនុប្បទាន វត្ថុដែលជាកម្មវត្ថុអាចស្ថិតក្នុងការកាន់កាប់របស់ម្ចាស់សិទ្ធិ ឬ វត្ថុអាចមិនស្ថិតក្នុងការកាន់កាប់របស់ម្ចាស់សិទ្ធិ។ ហានិភ័យអាចកើតមានឡើងអាស្រ័យទៅតាមករណីនីមួយៗ។

➢ ***<u>វត្ថុនៅក្នុងដៃម្ចាស់បំណុល</u>*៖**

ក្នុងករណីដែលការធ្វើកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន វត្ថុដែលជាកម្មវត្ថុត្រូវបានប្រគល់ដោយចំពោះមកឲ្យម្ចាស់សិទ្ធិ នោះបានសេចក្ដីថា ម្ចាស់សិទ្ធិត្រូវមានកាតព្វកិច្ចក្នុងការថែរក្សានូវវត្ថុនោះជំនួសឲ្យកូនបំណុល ដែលនេះហើយបានធ្វើឲ្យកើតមាននូវហានិភ័យដែលម្ចាស់បំណុលនឹងប្រឈម។ ក្នុងការបង្កើតឲ្យមាននូវកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន ភាគីណាជាអ្នកក្ដោបក្ដាប់វត្ថុ គឺភាគីនោះហើយជាអ្នកមានកាតព្វកិច្ចថែរក្សានូវវត្ថុដែលដាក់ជាកម្មវត្ថុនៃប្រាតិភោគ។ ព្យសនកម្មដែលកើតមានឡើងលើវត្ថុនឹងក្លាយទៅជាការទទួលខុសត្រូវរបស់ម្ចាស់បំណុល ឧទាហរណ៍ថា ក្នុងកិច្ចសន្យាប្រាតិភោគដោយអនុប្បទានដែល លោក ក ធ្វើកម្ចីប្រាក់ចំនួន ១០០០០ ដុល្លា (ពីរម៉ឺនដុល្លា) ពីលោក ខ ដោយយករថយន្តព្រូសជាកម្មវត្ថុនៃប្រាតិភោគហើយឲ្យលោក ខ ជាអ្នកកាន់កាប់រថយន្តនោះដោយចំពោះ។ ក្នុងឧទាហរណ៍នេះ ថ្ងៃមួយលោក ខ បានយករថយន្តព្រូសនោះមកជិះទៅផ្សារជិតផ្ទះ តែជាអកុសល់លោកបានជួបប្រទះនូវគ្រោះថ្នាក់ចរាចរណ៍ដែលបានបណ្ដាលឲ្យរថយន្តរបស់លោក ក ដែលបានយកមកដាក់ប្រាតិភោគដោយអនុប្បទាននោះ ត្រូវបានខូចខាតខ្ទិចខ្ទី។ ដូចករណីដែលបានលើកជាឧទាហរណ៍នេះ លោក ខ គឺត្រូវទទួលខុសត្រូវនូវព្យសនកម្មដែលកើតមានឡើងលើរថយន្តរបស់លោក ក ទាំងស្រុង។

➢ ***<u>វត្ថុមិននៅក្នុងដៃម្ចាស់បំណុល</u>*៖**

ទោះបីជាដូចបានលើកឡើងខាងលើនេះថាម្ចាស់បំណុលអាចទទួលរងនូវហានិភ័យកាលណាដែលវត្ថុស្ថិតនៅក្នុងកាន់កាប់របស់ខ្លួនក៏ដោយ មានករណីផ្សេងក្រៅពីការលើកឡើងខាងលើ ពោលគឺទោះវត្ថុមិននៅក្នុងដៃម្ចាស់បំណុល ក៏ហានិភ័យអាចនឹងកើត

មានឡើងផងដែរ។ ហានិភ័យដែលគួរឲ្យព្រួយបារម្ភបំផុតនោះនៅពេលដែលវត្ថុមិននៅក្នុងដៃរបស់ម្ចាស់បំណុលគឺ ការមិនទទួលបាននូវវត្ថុដែលជាកម្មវត្ថុនោះ។ ក្នុងការណ៍នេះ វាអាចមានពីរករណី ដែលទីមួយ គឺកូនបំណុលមិនព្រមធ្វើការប្រគល់វត្ថុមកឲ្យខ្លួននៅពេលដែលកិច្ចសន្យាត្រូវបានផុតកំណត់ ហើយប្រាក់កម្ចីពុំទាន់ធ្វើការសងជូនម្ចាស់សិទ្ធិវិញ។ រីឯករណីទីពីរវិញ គឺការមិនទទួលបានវត្ថុដោយសារក្នុងកំឡុងពេលកិច្ចសន្យាដោយសារវត្ថុនៅក្នុងដៃកូនបំណុល កូនបំណុលបានយកវត្ថុនោះធ្វើការលួចរត់បាត់ដែលយើងឃើញថាវាពិបាកចំពោះម្ចាស់បំណុលក្នុងការទារប្រាក់ត្រលប់មកវិញ។

ក្នុងការបកស្រាយខាងលើនេះ ការមិនអនុវត្តកាតព្វកិច្ចរបស់កូនបំណុល គឺបានធ្វើឲ្យយឺតយ៉ាវដល់ការសងប្រាក់ ហើយម្ចាស់បំណុលក៏ពិបាកក្នុងការដោះស្រាយផងដែរ ពោលគឺមានតែធ្វើការប្ដឹងទៅតុលាការដើម្បីឲ្យតុលាការពិនិត្យមើល និងចាត់វិធានការស្វែងរកកូនបំណុល។ ជាក់ស្ដែងវាអាចនឹងមានភាពពិបាកប្រសិនជាទំហំនៃទឹកប្រាក់នោះមានភាពតូចតាច ដោយហេតុថាតុលាការនឹងមិនធ្វើការដោះស្រាយភ្លាមៗនោះឡើយប្រសិនជាទំហំនោះតូចពេក ព្រោះតុលាការអាចនឹងខកខានក្នុងការដោះស្រាយនូវបញ្ហាមួយចំនួនធំទៀតដែលអាចមានផងប៉ះពាល់ធំធេង។

## ២. ករណីពាក់ព័ន្ធនឹងកូនបំណុល

ដោយឡែកពីហានិភ័យដែលអាចកើតមានឡើងលើម្ចាស់សិទ្ធិ កូនបំណុលក៏អាចមានភាគរយក្នុងការជួបប្រទះនូវហានិភ័យផងដែរ។ ដូចបានលើកឡើងខាងលើ ប្រាតិភោគដោយអនុប្បទានគឺបើកសិទ្ធិឲ្យគូភាគីធ្វើការចរចារលើការកាន់កាប់វត្ថុដែលជាកម្មវត្ថុ។ ហេតុដូចបានបញ្ជាក់នេះ ហានិភ័យអាចនឹងកើតមានឡើងជាពីរករណី ដែលដូចទៅនឹងម្ចាស់សិទ្ធិផងដែរ ពោលគឺករណីទីមួយសង្កត់ធ្ងន់ទៅលើវត្ថុនៅក្នុងដៃកូនបំណុល ហើយករណីទីពីរគឺវត្ថុមិននៅក្នុងដៃកូនបំណុល។

- ***<u>វត្ថុនៅក្នុងដៃកូនបំណុល</u>*៖**

វត្ថុដែលជាកម្មវត្ថុស្ថិតនៅក្នុងដៃកូនបំណុលដដែលកាលណាដែលម្ចាស់សិទ្ធិ គ្រាន់តែបានទទួលបាននូវការផ្ទេរការកាន់កាប់ដោយប្រយោល ពោលគឺជាការផ្ទេរលក្ខណៈរូបភាពខាងក្រៅតែប៉ុណ្ណោះ ហើយដែលករណីនេះភាគច្រើនកើតមានឡើងទៅលើចលនវត្ថុផ្ដុំគ្នា។ កូនបំណុលអាចទទួលរងនូវហានិភ័យដូចទៅនឹងករណីខាងលើរបស់

ម្ចាស់បំណុលដែរ គឺព្យសនកម្មលើវត្ថុដែលជាកម្មវត្ថុខ្លួនកំពុងកាន់កាប់។ កាតព្វកិច្ចក្នុងការថែរក្សាវត្ថុនោះឲ្យស្ថិតនៅស្ថានភាពល្អគឺសំខាន់ណាស់ចំពោះភាគីម្ខាងណាដែលជាអ្នកកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគ។ ប៉ុន្តែចំពោះករណីនៃចលនវត្ថុផ្គុំគ្នា កូនបំណុលគឺអាចមានសិទ្ធិធ្វើការចាត់ចែងលើវត្ថុនោះបាន ដោយគ្រាន់តែធានាថានឹងមានវត្ថុដើម្បីប្រគល់ទៅឲ្យម្ចាស់បំណុល ប្រសិនជាខ្លួនមិនបានធ្វើការសងប្រាក់ទាន់ពេលវេលាកំណត់នៃកិច្ចសន្យា។ ឧទាហរណ៍ថា លោក ក ខ្ចីប្រាក់លោក ខ ដោយយកឥវ៉ាន់ទាំងអស់នៅក្នុងហាងទំនិញរបស់លោកធ្វើការបញ្ចាំ លុះដល់ពេលផុតកំណត់សងលោក ក ស្រាប់តែគ្មានប្រាក់ នោះលោក ខ ក្នុងនាមជាម្ចាស់សិទ្ធិគឺមានសិទ្ធិអាចធ្វើការរឹបអូសទំនិញដែលត្រូវបានដាក់ប្រាតិភោគដោយអនុប្បទានក្នុងកិច្ចសន្យាបាន ដោយពុំចាំបាច់ទទួលការអនុញ្ញាតពីលោក ក នោះឡើយ។

ទោះបីជាកូនបំណុលជាអ្នកកាន់កាប់វត្ថុហើយព្យសនកម្មនោះក៏មិនសូវជាធំធេងក្នុងករណីចលនវត្ថុផ្គុំគ្នា ហានិភ័យនេះនៅតែជាកត្តាមួយដែលកូនបំណុលគួរយកចិត្តទុកដាក់ដើម្បីព្រោះថាកូនបំណុលអាចរងនូវហានិភ័យនេះ ដែលពិបាកក្នុងការដោះស្រាយ។ លើសពីនេះទៅទៀត បើយើងគិតទៅដល់ករណីប្រធានសក្តិវិញ ក៏វាមានភាពពិបាកផងដែរ។ គួរបញ្ជាក់ផងដែរថា ប្រធានសក្តិគឺជា ព្រឹត្តិការណ៍ ដែលកើតឡើងក្រៅពីឆន្ទៈមិនអាចប៉ាន់ស្មានជាមុន និងមិនអាចជម្នះបាន។[46] ដូចករណីនេះ បើក្នុងករណីជាក់ស្តែងទោះបីជានេះគឺករណីប្រធានសក្តិ ក៏កូនបំណុលមានកាតព្វកិច្ចមួយផ្នែកក្នុងការទទួលខុសត្រូវមួយផ្នែកលើវត្ថុនោះដែរ។

- ***<u>វត្ថុមិននៅក្នុងដៃកូនបំណុល</u>*** ៖

ប្រសិនជាវត្ថុមិននៅក្នុងដៃរបស់កូនបំណុលវិញ ហានិភ័យអាចនឹងមានទំហំតិចបើយើងមើលជាទូទៅ ហើយវាក៏ហាក់បីបង្ហាញជារូបភាពនៃការដាក់បញ្ចាំផងដែរ។ ទោះជាយ៉ាងណា ហានិភ័យក៏នៅតែជាកត្តាដែលជៀសមិនផុត ត្រង់ថាវត្ថុដែលស្ថិតនៅក្នុងដៃរបស់ម្ចាស់សិទ្ធិអាចនឹងទទួលរងនូវព្យសនកម្មដែលធ្វើឲ្យខូចខាតដល់ចលនវត្ថុ ដែលជាកម្មវត្ថុនៃប្រាតិភោគ។ ម្យ៉ាងវិញទៀត យើងដឹងហើយថា ជាធម្មតា វត្ថុដែលជាកម្មវត្ថុក្នុង

46 គណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, សន្ទានុក្រមផ្នែករដ្ឋប្បវេណី, បោះពុម្ពដោយទីស្តីការគណៈរដ្ឋមន្ត្រី, ឆ្នាំ ២០០៧ (ហៅថា សទ្ទានុក្រមផ្នែករដ្ឋប្បវេណី), ទំព័រ ១៥។

កិច្ចសន្យាប្រាតិភោគដោយអនុប្បទាន គឺតែងតែមានតម្លៃថ្លៃជាងចំនួនទឹកប្រាក់ដែលធ្វើខ្ចី ដូចនេះហើយវាអាចនឹងមានករណីដែលថាម្ចាស់បំណុលដោយសារចង់ទទួលការចំណេញហួសហេតុ បានយកវត្ថុនោះធ្វើការរត់គេចខ្លួន។ ក្នុងករណីនេះ វាមានលក្ខណៈស្មុគស្មាញ និងជាហានិភ័យដ៏ធ្ងន់ធ្ងរលើកូនបំណុល។

### កថាភាគទី ២៖ អាជ្ញាយុកាលនៃកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន

កិច្ចសន្យាទាំងឡាយតែងមានកាលកំណត់ដែលធ្វើឲ្យរលត់នូវសិទ្ធិរបស់គូភាគី ដូចគ្នាទៅនឹងកិច្ចសន្យាផ្សេងៗ។ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល សំដៅទៅលើការរលត់សិទ្ធិលើបំណុលដោយផ្អែកលើការណ៍ដែលម្ចាស់បំណុលមិនអនុវត្តសិទ្ធិ ក្នុងអំឡុងពេលដែលត្រូវបានកំណត់។[47] កិច្ចសន្យាប្រាតិភោគដោយអនុប្បទានក៏ដូចជាកិច្ចសន្យាដទៃទៀតផងដែរ ដែលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ត្រូវគិតចាប់ពីពេលដែលអាចអនុវត្តសិទ្ធិលើបំណុលនោះបាន។ បើយោងទៅតាមមាត្រា ៤៨២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិផ្សេងក្នុងក្រមនេះ ឬ ច្បាប់ឬបទដ្ឋានគតិយុត្តផ្សេង។ ដូចនេះ នៅក្នុងកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន ប្រសិនជាកិច្ចសន្យានោះលើសពីប្រាំឆ្នាំ កិច្ចសន្យានោះនឹងត្រូវបានផុតអាជ្ញាយុកាល។

[47] ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ៤៨០ ។

# សេចក្តីសន្និដ្ឋាន

ជារួមមក ប្រាតិភោគដោយអនុប្បទាននៅប្រទេសកម្ពុជាយើង គឺជាប្រភេទថ្មីមួយដែលទើបតែកើតមានឡើងក្នុងពេលបច្ចុប្បន្ន ដែលត្រូវបានប្រកាសឲ្យប្រើក្នុងពេលក្រមរដ្ឋប្បវេណីថ្មី ឆ្នាំ២០០៧ ចូលជាធរមាន។ ឆ្លងកាត់ការបកស្រាយខាងលើនេះ ប្រាតិភោគដោយអនុប្បទានកើតមានប្រភពចេញពីប្រទេសជប៉ុន ហើយដែលមានគោលបំណងជួយសម្រួលដល់ការអនុវត្តប្រាក់កម្ចីនៅក្នុងសង្គមកម្ពុជា ដែលការអនុវត្តត្រូវប្រព្រឹត្តទៅដោយគោរពទៅតាមល័ក្ខខ័ណ្ឌដែលបានកំណត់ក្នុងច្បាប់។ បុគ្គលទាំងឡាយណាដែលមានបំណងចង់បង្កើតកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន គឺរមែងត្រូវបំពេញនូវល័ក្ខខ័ណ្ឌគ្រឹះដែលជាល័ក្ខខ័ណ្ឌដ៏សំខាន់ដើម្បីឲ្យកិច្ចសន្យាមានសុពលភាពទៅតាមច្បាប់ជាធរមាន ក្នុងនោះល័ក្ខខ័ណ្ឌគ្រឹះ រួមមាន ការព្រមព្រៀង កម្មវត្ថុ និង សមត្ថភាព។ រីឯល័ក្ខខ័ណ្ឌផ្សេងដែលមានចែងក្នុងច្បាប់រួមមាន ល័ក្ខខ័ណ្ឌទម្រង់ និង ល័ក្ខខ័ណ្ឌតតាំង ដោយល័ក្ខខ័ណ្ឌទម្រង់ក្នុងការបង្កើតកិច្ចសន្យាប្រាតិភោគដោយអនុប្បទាននេះ គឺសំដៅទៅលើការព្រមព្រៀងរវាងគូភាគីកិច្ចសន្យា ដែលកិច្ចសន្យាអាចធ្វើជាទម្រង់នៃលិខិតឯកជន។ ច្បាប់ក៏បានបញ្ញត្តិផងដែរពាក់ព័ន្ធទៅនឹងការផ្ទេរការកាន់កាប់ ដែលជាល័ក្ខខ័ណ្ឌសម្រាប់តតាំងចំពោះតតិយជន ក្នុងករណីដែលអាចមានវិវាទកើតមានឡើង ហើយការផ្ទេរការកាន់កាប់នេះអាចប្រព្រឹត្តទៅបានតាមបួនរូបភាព គឺការប្រគល់ដោយជាក់ស្តែង ការប្តូរលក្ខណៈនៃការកាន់កាប់ ការប្រគល់ដោយសង្ខេប និង ការផ្ទេរការកាន់កាប់ដោយបញ្ជា។ ដូចបានបកស្រាយកន្លងមកអានុភាពនឹងកើតមានឡើងល្ហឹកណាដែលកិច្ចសន្យាត្រូវបានបង្កើតឡើង ហើយដែលបំពេញសព្វគ្រប់នូវល័ក្ខខ័ណ្ឌទាំងឡាយដែលមានបញ្ញត្តិ ដើម្បីឲ្យកិច្ចសន្យាមានអានុភាព។ ក្នុងការអនុវត្តវិញ កិច្ចសន្យាប្រាតិភោគដោយអនុប្បទានក៏ដូចទៅនឹងកិច្ចសន្យាប្រភេទផ្សេងៗផងដែរ ដែលតម្រូវឲ្យគូភាគីឈរលើគោលការណ៍នៃការព្រមព្រៀងក្នុងការបង្កើតកិច្ចសន្យា ។ ចំពោះកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន កិច្ចសន្យានឹងត្រូវបានបញ្ចប់នៅពេលដែលកាតព្វកិច្ចត្រូវបានអនុវត្ត ឬ បើកាតព្វកិច្ចមិនត្រូវបានអនុវត្ត ម្ចាស់សិទ្ធិនឹងអនុវត្តនូវសិទ្ធិរបស់ខ្លួនដោយធ្វើការចាត់ចែងលើវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា។

សរុបសេចក្តីមកវិញ យើងសង្កេតឃើញថា បទប្បញ្ញត្តិនៃប្រាតិភោគដោយអនុប្បទានគឺនៅមានចន្លោះខ្វះខាតដែលអ្នកច្បាប់គួរធ្វើការកែតម្រូវ និង ធ្វើការបន្ថែមនូវបទប្បញ្ញត្តិដើម្បីធ្វើយ៉ាង

ណាឲ្យវិសាលភាពនៃបញ្ញត្តិប្រាតិភោគដោយអនុប្បទាន គ្រប់ដណ្តប់ទៅលើការអនុវត្តជាក់ស្តែងឲ្យបានគ្រប់ជ្រុងជ្រោយ។ ឆ្លើយតបទៅនឹងការអនុវត្តក្នុងពេលបច្ចុប្បន្ន ការអនុវត្តពុំទាន់ចោទជាបញ្ហាធំនៅឡើយទេ ព្រោះថាប្រាតិភោគប្រភេទថ្មីនេះមានលក្ខណៈថ្មីស្រឡាងចំពោះបុគ្គលភាគច្រើន។ តែទោះជាយ៉ាងណា ការចែងនៅក្នុងក្រមរដ្ឋប្បវេណីនៅតែមិនទាន់មានភាពទូលំទូលាយដដែល ដែលជាចំណុចគួរយកចិត្តទុកដាក់នៅថ្ងៃខាងមុខ។

ក្នុងសេចក្តីសន្និដ្ឋានជារួម សារណារនេះគ្របដណ្តប់ទៅលើតែប្រាតិភោគដោយអនុប្បទាន ដែលក្នុងនោះបានរៀបរាប់យ៉ាងច្បាស់ពាក់ព័ន្ធនឹងរបបគតិយុត្តទូទៅ អានុភាព និង ការអនុវត្តជារួម។ កម្រងសារណារនេះបានបង្កនូវលក្ខណៈងាយស្រួលដល់មិត្តអ្នកអានទាំងឡាយ ក្នុងការស្វែងយល់ឲ្យកាន់តែច្បាស់លាស់ និង ស៊ីជម្រៅទៅលើប្រធានបទ ប្រាតិភោគដោយអនុប្បទាន៕

# អនុសាសន៍

ប្រទេសកម្ពុជាធ្លាប់បានជួបប្រទះនូវសោកនាតកម្មយ៉ាងជូរចត់ ជាហេតុបណ្តាលឲ្យឯកសារមួយចំនួនធំត្រូវបានបាត់បង់។ មិនតែប៉ុណ្ណោះ អ្នកប្រាជ្ញ អ្នកវិទ្យាសាស្ត្រ និង សាស្ត្រាចារ្យ ដែលមានចំណេះដឹងទាំងឡាយក៏បានលាចាកលោកផងដែរ ដែលជាហេតុធ្វើឲ្យប្រទេសយើងមានលក្ខណៈក្សត់នូវឯកសារនានា ហើយដែលជាហេតុទទួលបាននូវជំនួយពីបរទេស។ ច្បាប់កម្ពុជាភាគច្រើនមានជះឥទ្ធិពល និង ប្រភពចេញពីប្រទេសបារាំង ជប៉ុន ជាដើម ដោយសារប្រទេសទាំងនេះបានផ្តល់ជំនួយជាច្រើនមកកម្ពុជាយើង។ ដោយឡែក ប្រធានបទនៃសារណាមួយនេះ ពោលគឺប្រាតិភោគដោយអនុប្បទានក៏មានប្រភពចេញពីបរទេសផងដែរ ពោលគឺប្រទេសជប៉ុន ដែលនេះហើយបានធ្វើឲ្យចំណុចខ្លះគឺមិនសូវជាស្របទៅនឹងបដិបទនៃប្រទេសកម្ពុជាយើងនោះឡើយ។

ហេតុដូចបានពោលខាងលើនេះហើយ ច្បាប់នៃព្រះរាជាណាចក្រកម្ពុជាបានយកគោលគំនិតនៃបញ្ញត្តិស្តីពីប្រាតិភោគដោយអនុប្បទាន យកធ្វើការកែប្រែធ្វើយ៉ាងណាឲ្យមានលក្ខណៈសមស្របទៅបដិបទនៃប្រទេសកម្ពុជាយើង។ ទោះជាយ៉ាងណាក៏ដោយ ដោយសារបញ្ញត្តិមួយនេះជាបញ្ញត្តិដ៏ថ្មីស្រឡាង នាំឲ្យវិសាលភាពនៃប្រាតិភោគដោយអនុប្បទាននៅមានកំណត់ និងមិនបានគ្របដណ្តប់គ្រប់ជ្រុងជ្រោយ។ ការណ៍ដែលមានចំណុចខ្វះខាតបែបនេះ គឺដោយសារថាបុគ្គលទាំងឡាយមិនសូវមានការយល់ដឹងអំពីប្រាតិភោគប្រត្យក្សប្រភេទថ្មីនេះ ហេតុនេះហើយបណ្តាលឲ្យការអនុវត្តនៅមានភាពខុសឆ្គង។

ឆ្លងតាមការស្រាវជ្រាវលើប្រធានបទនៃសារណារនេះ យើងឃើញថា ប្រាតិភោគដោយអនុប្បទាននៅតែមានចំណុចខ្វះខាត ដែលអ្នកសិក្សាស្រាវជ្រាវ និស្សិត និង អ្នកបំពេញវិជ្ជាជីវៈខាងផ្នែកច្បាប់ទាំងឡាយ គួរគប្បីយកចិត្តទុកដាក់ទៅលើបញ្ហាប្រាតិភោគនេះ ដើម្បីឲ្យការអនុវត្តទៅថ្ងៃខាងមុខជៀសឲ្យផុតពីបញ្ហាប្រឈមដែលអាចនឹងកើតមានឡើង។ ដោយហេតុថា ប្រាតិភោគដោយអនុប្បទានពុំមែនជាបញ្ញត្តិចាស់ ដូចនេះហើយបានជាការអនុវត្តនៅមានភាពខុសឆ្គង និងមានចន្លោះខ្វះខាត ហើយបញ្ញត្តិទាំងនេះ ក៏ពុំបានក្តោបនូវចំណុច និង ស្ថានភាពទាំងឡាយឲ្យបានគ្រប់ករណីផងដែរ។

សរុបមកវិញ ជាអនុសាសន៍រួម កម្ពុជាយើងគួរតែៈ

១- ធ្វើការផ្សព្វផ្សាយនូវពត៌មានទាក់ទិននឹងបញ្ញត្តិស្តីពី ប្រាតិភោគដោយអនុប្បទាន ដើម្បីឲ្យប្រជាពលរដ្ឋក្នុងសង្គមមានការយល់ដឹងឲ្យកាន់តែច្រើន លម្អិត និងស៊ីជម្រៅ ក្នុងគោលបំណងកាត់បន្ថយនូវការភ័ន្តច្រឡំ ក៏ដូចជា ការអនុវត្តខុសពីបញ្ញត្តិក្នុងច្បាប់ដែលអាចបណ្តាលឲ្យកើតមាន

នូវវិវាទកាន់តែច្រើន។

២- ធ្វើការបំពេញបន្ថែម និង ពង្រឹងនូវល័ក្ខខ័ណ្ឌក្នុងការអនុវត្តប្រាតិភោគដោយអនុប្បទាន ដែលក្នុងន័យនេះសំដៅទៅលើល័ក្ខខ័ណ្ឌតតាំង ដោយហេតុថា ក្នុងការតតាំងនឹងតតិយជន ម្ចាស់សិទ្ធិនៅក្នុងរឿងប្រាតិភោគដោយអនុប្បទាននេះ ពុំសូវជាទទួលបាននូវការធានាមួយដែលជាក់លាក់នោះទេ ពោលគឺក្នុងករណីភាគច្រើនគឺនៅតែពុំអាចតតាំងនឹងតតិយជនបានដដែល។ ដូចករណីដែលការកាន់កាប់វត្ថុនៅក្នុងដៃរបស់កូនបំណុល ម្ចាស់បំណុលហាក់ដូចជាមិនបានទទួលអ្វីជាការធានាទាល់តែសស់ ដោយការធ្វើប្រាតិភោគដោយអនុប្បទាននេះពុំមានធ្វើការចុះបញ្ជីអ្វីឡើយ។

ក្នុងពេលអនាគត ប្រសិនជាកម្ពុជាយើងអាចធ្វើការកែប្រែ ពង្រីក និង ពង្រឹងនូវបទប្បញ្ញត្តិទាំងឡាយស្តីពីប្រាតិភោគដោយអនុប្បទាន និង អាចធ្វើការកែតម្រូវដូចបានលើកឡើងខាងលើនាងខ្ញុំប្រាកដថា នីតិវិធីនៃប្រាតិភោគដោយអនុប្បទាននឹងមានភាពច្បាស់លាស់ និង ទទួលបានការធានាកាន់តែល្អប្រសើរ។ ម្យ៉ាងវិញទៀត ការកែតម្រូវទៅលើបញ្ញត្តិទាំងនេះនឹងអាចជួយសម្រួលដល់ការអនុវត្ត និង ចំណេះដឹងរបស់ប្រជាពលរដ្ឋក្នុងសង្គម ក៏ដូចជាអាចកាត់បន្ថយនូវវិវាទកាន់តែច្រើនផងដែរ៕